GCCF Gulf Coast Claims Facility
www.GulfCoastClaimsFacility.com

# ស្ថាប័នសម្របសម្រួល ពាក្យបណ្ដឹងទាមទារសំណង សម្រាប់តំបន់ឆ្នេរជាប់ឈូងសមុទ្រ
# ការសម្របសម្រួលការទាមទារសំណងតាមតំបន់ឆ្នេរឈូងសមុទ្រ
# លក្ខណវិនិច្ឆ័យលើសិទ្ធិស្របច្បាប់ និងការបង្ហាញភស្តុតាង និងវិធីសាស្ត្រ
# ការបង្ហាញភស្តុតាង និងវិធីសាស្ត្រផ្តល់សំណងចុងក្រោយ

## ថ្ងៃទី18 ខែកុម្ភៈ ឆ្នាំ2011

ការសម្របសម្រួលការទាមទារសំណងតាមតំបន់ឆ្នេរឈូងសមុទ្រ ("FCCF") សូមធ្វើការប្រកាសនូវវិធានស្ថាពររបស់ខ្លួនដែលគ្រប់គ្រងលើជម្រើសក្នុងការផ្តល់សំណង លក្ខណវិនិច្ឆ័យលើសិទ្ធិស្របច្បាប់ និងការបង្ហាញភស្តុតាង និងវិធីសាស្ត្រផ្តល់សំណងចុងក្រោយ ("វិធានស្ថាពរ")។ GCCF កំពុងដើរតួនាទីជំនួស និងក្នុងនាមក្រុមហ៊ុន BP ក្នុងការបំពេញកាតព្វកិច្ចផ្លូវច្បាប់ក្នុងនាមជា "ភាគីទទួលខុសត្រូវ" ស្ថិតក្រោមច្បាប់ស្តីពីការបំពុលដោយប្រេងឆ្នាំ1990។ រាល់អ្នកទាមទារសំណងទាំងអស់មានសិទ្ធិគ្រប់គ្រាន់ក្នុងការពិគ្រោះជាមួយមេធាវីដែលខ្លួនបានជ្រើសរើស មុនធ្វើការទទួលយកដំណោះស្រាយណាមួយ ឬក៏ចុះហត្ថលេខាលើលិខិតដោះបន្ទុកកាតព្វកិច្ច។

## I. សេចក្តីផ្តើម

ឯកសារនេះពិពណ៌នាអំពី៖ 1) លក្ខណៈវិនិច្ឆ័យលើសិទ្ធិស្របច្បាប់ដែលតម្រូវឱ្យអ្នកទាមទារសំណងជាលក្ខណៈឯកជន លក្ខណៈបុគ្គល និងលក្ខណៈអាជីវកម្មទាំងអស់ដាក់បណ្តឹងទាមទារទៅ GCCF ដើម្បីទាមទារឱ្យមានការផ្តល់សំណងចុងក្រោយ ឬ ការផ្តល់សំណងបណ្តោះអាសន្ន ពី GCCF 2) វិធីសាស្ត្រនៃការគណនាដែលកំពង់ប្រើប្រាស់ដោយ GCCF ដើម្បីកំណត់ទំហំប្រាក់សំណងដែលអ្នកទាមទារចង់បាន 3) ការតម្រូវឱ្យមានសំណុំឯកសារគ្រប់គ្រាន់ជាមុនដើម្បីទទួលបានប្រាក់សំណង និង 4) នីតិវិធីថ្មីដែលបង្កើតឡើងដើម្បីបង្កើនតម្លាភាព និងសង្គតភាពឱ្យកាន់តែខ្លាំងនៅក្នុងដំណើរការទាមទារសំណងរបស់ GCCF។

នៅថ្ងៃទី2 ខែកុម្ភៈ ឆ្នាំ2011 GCCF បានចេញផ្សាយសេចក្តីប្រកាសព្រាងមួយស្តីពីជម្រើសនៃការផ្តល់សំណង លក្ខណៈវិនិច្ឆ័យលើសិទ្ធិស្របច្បាប់ និងការបង្ហាញភស្តុតាង និងវិធីសាស្ត្រផ្តល់សំណងចុងក្រោយ។ ក្នុងកិច្ចខិតខំប្រឹងប្រែងមួយដើម្បីជំរុញឱ្យមានការលាតត្រដាង និងតម្លាភាពពេញលេញ នៅក្នុងសេចក្តីប្រកាសរបស់ GCCF បានសំណូមពរឱ្យមានការផ្តល់មតិយោបល់ជាសាធារណៈក្នុងអំឡុងពេលចាប់ពីថ្ងៃទី 2 ខែកុម្ភៈ ដល់ថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ 2011 ពីសំណាក់អ្នកប្តឹងទាមទារទាំងអស់ និងភាគីផ្សេងទៀតដែលចាប់អារម្មណ៍។

ក្នុងអំឡុងពេល 2 សប្តាហ៍ដំបូង GCCF បានទទួលមតិយោបល់ចំនួន 1 440 ពីអ្នកប្តឹងទាមទារ ក្រុមហ៊ុនអាជីវកម្ម អ្នកជំនាញ មន្ត្រីរាជការ និងភាគីផ្សេងទៀតដែលចាប់អារម្មណ៍ ដោយក្នុងនោះពួកគេបានបញ្ចេញមតិយោបល់ផ្សេងៗពាក់ព័ន្ធនឹងបញ្ហាទាំងនេះ និងបញ្ហាពាក់ព័ន្ធដទៃទៀត។ មតិយោបល់ទាំងនេះត្រូវបានដាក់បង្ហាញជាសាធារណៈនៅលើគេហទំព័ររបស់ GCCF(www.gulfcoastclaimsfacility.com.). GCCF បានពិចារណាលើមតិយោបល់ទាំងអស់ដោយយកចិត្តទុកដាក់នៅក្នុងសេចក្តីព្រាងវិធានស្ថាពរទាំងនេះ ហើយជាការឆ្លើយតបទៅនឹងមតិយោបល់ទាំងនោះ យើងបានកែសម្រួលសំណើររបស់ខ្លួនមួយចំនួនទៅលើសេចក្តីប្រកាសព្រាងដែលបានចេញផ្សាយនៅថ្ងៃទី2 ខែកុម្ភៈ ឆ្នាំ2011។

GCCF បន្តឈ្វេងយល់ឱ្យបានលំទូលាយអំពីផលប៉ះពាល់ដែលបង្កឡើងដោយឧបទ្ទវហេតុDeepwater Horizon Incident ("ការហៀរប្រេង") និងលទ្ធផលរបស់វាក្នុងពេលក្រោយមក។ អ្នកជំនាញដែលបង្កើតឡើងដោយ GCCF បានធ្វើការស្រាវជ្រាវ និងសិក្សាលើរបាយការណ៍ និងទិន្នន័យផ្សេងៗគ្នាជាច្រើនពាក់ព័ន្ធនឹងអនាគតរបស់ឈូងសមុទ្រ និងបានចងក្រងជាឯកសារយោងជាច្រើន។ រាល់ឯកសារទាំងនេះត្រូវបានដាក់បង្ហាញនៅលើគេហទំព័ររបស់ GCCF នៅថ្ងៃទី 2 ខែកុម្ភៈ ឆ្នាំ2011 ហើយអាចមើលឡើងវិញនៅលើវែបសាយ www.GulfCoastClaimsFacility.com. នៅក្នុងការអនុម័តវិធានស្ថាពររបស់ខ្លួនដែលគ្រប់គ្រងលើការផ្តល់សំណងចំពោះការទាមទារចុងក្រោយ និងការទាមទារបណ្តោះអាសន្ន GCCF បានប្រមូលអង្គហេតុ និងមតិយោបល់ពីប្រភពផ្សេងៗជាច្រើនក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតកម្មវិធីទូទាត់សំណងមួយដែលទុកចិត្តបាន និងមានយុត្តិធម៌។

ជាមួយនឹងការប្រកាសឱ្យប្រើប្រាស់វិធានស្តាពរ នៅពេលនេះ GCCF នឹងចាប់ផ្តើមជំហានបន្ទាប់នៃកម្មវិធីទូទាត់សំណង: ការផ្តល់សំណងដល់ការទាមទារចុងក្រោយ និងការទាមទារបណ្តោះអាសន្នរបស់អ្នកប្តឹងទាមទារទាំងឡាយដែលទទួលរងការខូចខាតដោយសារការកំពប់ប្រេងនេះ។ អ្នកប្តឹងទាមទារទាំងអស់គួរពិចារណាដោយយកចិត្តទុកដាក់ទៅលើជម្រើសចំនួន3:

1. ការបង់ប្រាក់ចុងក្រោយ៖ ការផ្តល់សំណងចុងក្រោយ: ការផ្តល់សំណងចុងក្រោយនឹងផ្តល់ឱ្យជាសំណងថ្លៃខូចខាតដល់អ្នកប្តឹងទាមទារចំពោះការខូចខាតពីមុនទាំងអស់ដែលមានឯកសារបញ្ជាក់ បូកនឹងការខូចខាតនាពេលអនាគតដែលបានប៉ាន់ស្មានបង្កឡើងដោយការកំពប់ប្រេងនេះ ហើយនឹងដោះស្រាយនូវរាល់ការទាមទារទាំងអស់របស់អ្នកប្តឹងទាមទារប្រឆាំងនឹងក្រុមហ៊ុន BP និងភាគីសំខាន់ៗផ្សេងទៀតដែលត្រូវទទួលខុសត្រូវចំពោះការខូចខាតណាមួយ និងទាំងអស់ក្នុងពេលអតីតកាល និងការខូចខាតក្នុងពេលអនាគត។ **ដើម្បីទទួលបានការផ្តល់សំណងចុងក្រោយ អ្នកប្តឹងទាមទារត្រូវបានតម្រូវឱ្យចុះហត្ថលេខាលើឯកសាររួចផុតបន្ទុកដែលរារាំងអ្នកប្តឹងទាមទារពីការទាមទារប្រាក់សំណងបន្ថែមទៀតពី GCCF ពីឆ្នាំសមុទ្រ ឬ ពីក្រុមហ៊ុន BP ឬ ក្រុមហ៊ុនចុងចោទមួយចំនួនផ្សេងទៀតដែលត្រូវទទួលខុសត្រូវចំពោះការកំពប់ប្រេងនេះ។**

2. ការផ្តល់សំណងបណ្តោះអាសន្ន: ការផ្តល់សំណងបណ្តោះអាសន្ននឹងផ្តល់នូវសំណងថ្លៃខូចខាតដល់អ្នកប្តឹងទាមទារចំពោះការខូចខាតពីមុនដែលបង្កឡើងដោយសារការកំពប់ប្រេងនេះ ដោយមានឯកសារបញ្ជាក់ច្បាស់លាស់ ហើយរាល់ការខូចខាតត្រូវតែមានឯកសារបញ្ជាក់ ប៉ុន្តែ **មិនតម្រូវឱ្យមានឯកសាររួចផុតបន្ទុកឡើយ។** ស្ថិតក្រោមជម្រើសនេះ អ្នកប្តឹងទាមទារអាចត្រឡប់ទៅ GCCF វិញម្តងទៀតក្នុងត្រីមាសនីមួយៗនៃឆ្នាំប្រតិទិនដើម្បីស្វែងរកសំណងចំពោះការខូចខាតបន្ថែមទៀតកាលពីអតីតកាលដែលមានឯកសារបញ្ជាក់។ ជម្រើសផ្តល់សំណងបណ្តោះអាសន្ននេះមិនតម្រូវឱ្យអ្នកប្តឹងទាមទារបោះបង់ចោលសិទ្ធិបណ្តឹងរបស់គេនោះឡើយ។

3. "ការផ្តល់សំណងភ្លាមៗ:" ជាការផ្តល់សំណងភ្លាមៗដែលមានប្រាក់ចំនួន 5 000 ដុល្លារអាមេរិក ដល់អ្នកប្តឹងទាមទារជាបុគ្គល, 25 000 ដុល្លារអាមេរិក ដល់អ្នកប្តឹងទាមទារជាអាជីវករ។ ជម្រើសនេះអាចមានសម្រាប់អ្នកប្តឹងទាមទារដែលបានទទួល ជម្រើសនេះ អាចមានសម្រាប់អ្នកប្តឹងទាមទារដែលបានទទួលការផ្តល់សំណងបន្ទាន់ជាមុន ឬ ការផ្តល់សំណងបណ្តោះអាសន្នពី GCCF ដោយមិនតម្រូវឱ្យអ្នកប្តឹងទាមទារនោះផ្តល់នូវសំណុំឯកសារបន្ថែម។ **ជម្រើសផ្តល់សំណងភ្លាមៗនេះនឹងអមទៅដោយឯកសាររួចផុតបន្ទុកទាំងស្រុង ដែលរារាំងអ្នកប្តឹងទាមទារពីការស្វែងរកសំណងបន្ថែមពី GCCF ឆ្នាំសមុទ្រ ឬ ក្រុមហ៊ុន BP ឬ ក្រុមហ៊ុនចុងចោទមួយចំនួនផ្សេងទៀតដែលត្រូវទទួលខុសត្រូវចំពោះការហៀរប្រេង។**

## II. លក្ខណៈវិនិច្ឆ័យលើសិទ្ធិស្របច្បាប់

GCCF បានអនុម័តនូវគោលការណ៍មួយចំនួនដូចខាងក្រោមដែលគ្រប់គ្រងលើលក្ខណៈវិនិច្ឆ័យអំពីសិទ្ធិស្របច្បាប់ដែល អាចអនុវត្តបានចំពោះការទាមទារសំណងចុងក្រោយ និងសំណងបណ្តោះអាសន្នសម្រាប់បុគ្គល និងអាជីវកម្ម។

1. បុគ្គលគ្រប់រូប និងអាជីវកម្មទាំងអស់ដែលទទួលរងការខាតបង់ដោយសារការកំពប់ប្រេងនេះមានសិទ្ធិ និងត្រូវបានលើកទឹកចិត្តឱ្យដាក់បណ្តឹងទាមទារសំណងចុង ឬ សំណងបណ្តោះអាសន្នទៅ GCCF។ មិនថារាងកាយស្ថិតនៅជិតការកំពប់ប្រេង ឬ ប្រភេទការងារ ឬ អាជីវកម្មណាមួយដែលពាក់ព័ន្ធនោះទេ អ្នកប្តឹងទាមទារ គឺតម្រូវឱ្យបញ្ជាក់ជាមុននូវសិទ្ធិស្របច្បាប់ដើម្បីទទួលបានសំណងតាមការទាមទារ។ ***ប៉ុន្តែតម្រូវឱ្យមានសំណុំឯកសារគ្រប់គ្រាន់ស្តីពីការខូចខាតដែលបង្កឡើងដោយការកំពប់ប្រេងនេះ***។ រាងកាយស្ថិតនៅជិតការហៀរប្រេង និងស្ថានភាពអាជីវកម្ម ឬ ការងារដែលលើកឡើងដោយអ្នកប្តឹងទាមទារ សុទ្ធតែជាកត្តាសំខាន់សម្រាប់ជាភស្តុតាងដើម្បីរៀបចំពាក្យប្តឹងទាមទារចំពោះការខូចខាតដែលបង្កឡើងដោយការកំពប់ប្រេងនេះ។ (មើលចំណុច IV ខាងក្រោម)។ អ្នកប្តឹងទាមទារត្រូវមានសមត្ថភាពពន្យល់ពីការខូចខាតដែលបានចោទប្រកាន់ទាក់ទងនឹងការកំពប់ប្រេងនេះ ដោយមិនគិតពីកត្តាដទៃទៀត ដូចជា ការធ្លាក់ចុះជាទូទៅនូវសេដ្ឋកិច្ចតាមតំបន់ឈូងសមុទ្រ ឬ អស្ថេរភាពហិរញ្ញវត្ថុដទៃទៀតដែលមិនពាក់ព័ន្ធនឹងការកំពប់ប្រេង។ (មើលឯកសារភ្ជាប់ A។)

2. GCCF នឹងវាយតម្លៃលើបណ្តឹងទាមទារនីមួយៗដើម្បីកំណត់ថា តើការខាតបង់នោះបង្កឡើងដោយការហៀរប្រេង ឬ អត់។ បណ្តឹងទាមទារនីមួយៗ គឺផ្អែកលើខ្លឹមសារផ្ទាល់របស់វា។ គ្រប់ករណីទាំងអស់ត្រូវតែមានទំនាក់ទំនងដែលអាចកំណត់បានរវាងការខាតបង់ជាក់ស្តែង និងការកំពប់ប្រេង។ ដូច្នេះហើយ តម្រូវឱ្យមានភស្តុតាងបញ្ជាក់ពីទំនាក់ទំនងនេះ។

3. អ្នកទាមទារដែលត្រូវបានចាត់ទុកថា មិនមានសិទ្ធិទទួលបានសំណងបន្ទាន់ជាមុនពី GCCF ត្រូវបានអញ្ជើញឱ្យដាក់ពាក្យទាមទារឡើងវិញដើម្បីស្វែងរកការផ្តល់សំណងចុងក្រោយ ឬ ការផ្តល់សំណងបណ្តោះអាសន្ន ដោយអមមកជាមួយនូវសំណុំឯកសារដែលបញ្ជាក់ពីទំនាក់ទំនងទៅនឹងការកំពប់ប្រេងនេះ។

4. បុគ្គលទាំងឡាយដែលរងរបួសដល់រាងកាយ ឬ ដែលតំណាងឱ្យសាច់ញាតិដែលស្លាប់ដោយសារការហៀរប្រេងនេះមានសិទ្ធិទទួលបានសំណងពី GCCF។ ការទាមទារបែបនេះត្រូវមានឯកសារដែលបង្ហាញ ថាការរងរបួសលើរាងកាយ ឬ ការស្លាប់នោះ គឺដោយសារតែការកំពប់ប្រេងនេះ មិនមែនដោយសារមូលហេតុផ្សេងទៀតនោះទេ។ ក្នុងករណីដែលអ្នកប្តឹងទាមទារបង្ហាញពីពិការភាពបង្កឡើងដោយការកំពប់ប្រេង គេត្រូវមានភស្តុតាងបញ្ជាក់ពីពិការភាពផ្នែកណាមួយ ឬ ពិការភាពអចិន្ត្រៃយ៍ (ដូចជា ប្រាក់ធានារ៉ាប់រងសង្គម ឬ ការកំណត់សំណងរបស់ពលកររបស់រដ្ឋលើពិការភាព) ដើម្បីកំណត់ពីវិសាលភាពនៃផលប៉ះពាល់រយៈពេលយូរទៅលើសមត្ថភាពរបស់អ្នកទាមទារក្នុងការធ្វើការងារក្នុងអាជីពណាមួយដែលគាត់ជ្រើសរើស។

5. បុគ្គល និងអាជីវកម្មដែលទាមទារសំណងថ្លៃខូចខាតលើទ្រព្យសម្បត្តិផ្ទាល់ខ្លួន ឬ អចលនទ្រព្យ មានសិទ្ធិទទួលបានសំណងពី GCCF។

6. បុគ្គលដែលប្រើប្រាស់ធនធានធម្មជាតិដែលទទួលរងការខូចខាត ឬបំផ្លិចបំផ្លាញដោយសារការកំពប់ប្រេង ដើម្បីទទួលបានអាហារ ទីជម្រក សម្លៀកបំពាក់ ឱសថ ឬ ការប្រើប្រាស់ផ្សេងៗទៀតដើម្បីចិញ្ចឹមជីវិត មានសិទ្ធិទទួលបានសំណងពី GCCF។

**7. បណ្ដឹងទាមទារពាក់ព័ន្ធនឹងការអាក់ខានសកម្មភាពខូងក្នុងតំបន់ទឹកជ្រៅ បណ្ដឹងទាមទារសំណងខូចខាតទ្រព្យសម្បត្តិសម្រាប់កប៉ាល់ដែលប្រើប្រាស់នៅក្នុងកម្មវិធីកប៉ាល់ផ្ដល់ ឱកាស (Vessels of Opportunity Program) និងបណ្ដឹងទាមទារដែលធ្វើឡើងដោយអង្គភាពរដ្ឋាភិបាល គឺមិនមានសិទ្ធិទទួលបានសំណងពី GCCF ឡើយ។**

## III. ការគណនាអំពីការផ្ដល់ឱ្យសំណងចុងក្រោយ និងសំណងបណ្ដោះអាសន្ន

GCCF មានអ្នកជំនាញផ្នែកវិទ្យាសាស្ត្រ និងសេដ្ឋកិច្ចសម្រាប់ធ្វើការស្រាវជ្រាវឱ្យបានទូលំទូលាយ និងត្រួតពិនិត្យឡើងវិញនូវការសិក្សានានាពាក់ព័ន្ធនឹងផលប៉ះពាល់នៃការកំពប់ប្រេងទៅលើធនធាននៅតាមឈូងសមុទ្រ។ អ្នកជំនាញទាំងនេះបានត្រួតពិនិត្យលើការសិក្សាជាច្រើនដែលវិភាគអំពីអត្រាងើបឡើងវិញនៃសេដ្ឋកិច្ចពីព្រឹត្តិការណ៍មហន្តរាយសំខាន់ៗដទៃទៀតដែលជះឥទ្ធិពលទៅលើវិស័យទេសចរណ៍។ លើសពីនេះទៀត GCCF បានប្រឹក្សាយោបល់ជាមួយបុគ្គល និងអាជីវកម្មជាច្រើនដែលស្ថិតនៅក្នុងតំបន់ឈូងសមុទ្រដើម្បីឈ្វេងយល់ពីផលប៉ះពាល់ដែលអាចកើតមានចំពោះបុគ្គល និងអាជីវកម្មនៅតាមឈូងសមទ្រដោយសារតែការកំពប់ប្រេងនេះ។ ចុងក្រោយ GCCF បានទទួលផលប្រយោជន៍ពីមតិយោបល់របស់អ្នកប្ដឹងទាមទារ អ្នកជំនាញ និងភាគីពាក់ព័ន្ធដទៃទៀត ក្នុងអំឡុងពេលនៃការផ្ដល់មតិយោបល់រយៈពេល 2សប្ដាហ៍ថ្មីៗនេះ។ គោលដៅរបស់ GCCF គឺដើម្បីកំណត់ផលប៉ះពាល់ពីការហៀរប្រេងទៅលើការប្រមូលផលអាហារសមុទ្រ ឧស្សាហកម្មទេសចរណ៍ និងឥទ្ធិពលផ្សេងទៀតទៅលើសេដ្ឋកិច្ចរបស់ឈូងសមុទ្រជាទូទៅ។ កិច្ចខិតខំប្រឹងប្រែងមួយត្រូវបានធ្វើឡើងដោយ GCCF ដើម្បីកំណត់រយៈពេលប្រហាក់ប្រហែលសម្រាប់ការងើបឡើងវិញនៃសេដ្ឋកិច្ចពេញលេញ និងទម្រង់នៃការងើបឡើងវិញបន្តិចម្ដងៗក្នុងរយៈពេលមួយ។

GCCF នឹងផ្ដោតការគណនាអំពីការផ្ដល់សំណងបណ្ដោះអាសន្នរបស់ខ្លួនទៅលើការខាតបង់ជាក់ស្ដែងដែលមានឯកសារបញ្ជាក់ ដែលទទួលរងដោយអ្នកទាមទារនៅក្នុងអំឡុងពេលក្រោយពីការកំពប់ប្រេងភ្លាមៗនៅថ្ងៃទី 20 ខែមេសា ឆ្នាំ2010 និងជាកាលបរិច្ឆេទនៃការដាក់ពាក្យប្ដឹងទាមទារសំណងបណ្ដោះអាសន្ន។ ចំពោះការផ្ដល់សំណងចុងក្រោយ GCCF នឹងផ្ដោតការគណនារបស់ខ្លួនទៅលើកត្តាសំខាន់ចំនួន 2 : 1) ការខាតបង់ជាក់ស្ដែងរបស់អ្នកទាមទារដោយមានឯកសារបញ្ជាក់គិតចាប់ពីកាលបរិច្ឆេទដែលការខាតបង់កើតឡើងចាប់តាំងពីមានការកំពប់ប្រេងនៅខែមេសា ឆ្នាំ2010 2) កត្តាកើតឡើងវិញដើម្បីវាយតម្លៃហានិភ័យនៃការខាតបង់នាពេលអនាគតដែលអាចកើតមានដូចបានកំណត់ដោយអ្នកជំនាញ និងការរួមចំណែកផ្សេងទៀតដែលទទួលបានក្នុងអំឡុងពេលផ្ដល់មតិយោបល់ជាសាធារណៈ។

បន្ទាប់ពីបានពិនិត្យលើទស្សនៈរបស់អ្នកជំនាញ ការសិក្សានានា របាយការណ៍ និងមតិយោបល់ជាសាធារណៈ GCCF មានជំនឿថា ផ្អែកលើព័ត៌មានដែលមានស្រាប់:

1. មានភស្តុតាងបង្ហាញពីការចាប់ផ្ដើមងើបឡើងវិញខ្លាំងក្លានៃសេដ្ឋកិច្ច។ ប៉ុន្តែ GCCF បានសន្និដ្ឋានថា វាគឺជាការសមហេតុផលដែលត្រូវផ្អែកការគណនាអំពីការផ្ដល់សំណងនាពេលអនាគតរបស់ខ្លួនទៅលើគោលការណ៍ដែលការកើតឡើងវិញនៃសេដ្ឋកិច្ចពេញលេញនៅតាមតំបន់ឈូងសមុទ្រទំនងជាកើតឡើង (ប៉ុន្តែមិនប្រាកដ) នៅក្នុងអំឡុងពេលពី 2 ទៅ 3ឆ្នាំ បន្ទាប់ពីពេលកំពប់ប្រេង។

2. ការព្យាករណ៍មិនមែនជាវិទ្យាសាស្ត្រពិតនោះទេ។ ដោយសារភាពមិនប្រាដកប្រជានៅតែបន្តកើតមាននោះ GCCF មានជំនឿថា វាជាការសមស្របក្នុងការផ្ដល់ឱ្យអ្នកទាមទារសំណងដែលមានបំណងចុងក្រោយក្នុងការដោះស្រាយការទាមទាររបស់ខ្លួនក្នុងពេលនេះ នូវសំណងដែលទូទាត់សម្រាប់ភាពមិនប្រាកដប្រជាពាក់ព័ន្ធដល់ថ្ងៃក្រោយ ។

3. ការគណនារបស់ GCCF គឺពឹងផ្អែកទៅលើទិន្នន័យបច្ចុប្បន្ន ទស្សនៈរបស់អ្នកជំនាញ និងមតិយោបល់ដែលបានផ្ដល់ដោយអ្នកប្ដឹងទាមទារ និងភាគីពាក់ព័ន្ធផ្សេងៗទៀតក្នុងអំឡុងពេលនៃការផ្ដល់មតិយោបល់ជាសាធារណៈ។ GCCF នឹងធ្វើការវាយតម្លៃបន្តលើទិន្នន័យដែលមានជារៀងរាល់ 4ខែម្ដង។ ប្រសិនបើការវាយតម្លៃឡើងវិញបង្ហាញឱ្យឃើញនូវការប្រែប្រួលពាក់ព័ន្ធនឹងអស្ថេរភាពនាពេលអនាគតដែលតម្រូវឱ្យមានការកែសម្រួលចំពោះការសងសំណងសម្រាប់ហានិភ័យនាពេលអនាគត នោះGCCF នឹងធ្វើការកែសម្រួលយ៉ាងសមស្រប ហើយអនុវត្តការកែសម្រួលនេះទៅលើបណ្ដឹងទាមទារទាំងអស់ដែលបានប្ដឹងចាប់ពីពេលនោះតទៅ។ ទោះបីជាយ៉ាងណាក៏ដោយ បណ្ដឹងទាមទារសំណងចុងក្រោយដែលបានដាក់កាលពីពេលមុនដោយមានឯកសារបញ្ជាក់គ្រប់គ្រាន់ ប៉ុន្តែមិនទាន់ត្រូវបានវាយតម្លៃនោះ នឹងទទួលបានសំណងខ្ពស់ជាងសម្រាប់កត្តាងើបឡើងវិញនាពេលអនាគតដែលមានសុពលភាពនៅពេលដែលបណ្ដឹងទាមទារត្រូវបានដាក់បញ្ជូនមមកដោយមានឯកសារបញ្ជាក់ពេញលេញ ឬ កត្តាងើបឡើងវិញនាពេលអនាគតដែលត្រូវបានកែសម្រួល។

4. <u>អ្នកទាមទារសំណងណាម្នាក់ដែលមិនឯកភាពទៅនឹងវិធីសាស្ត្ររបស់ GCCF ពាក់ព័ន្ធនឹងការគណនាសំណងនាពេលអនាគត ឬ មិនទាន់ទទួលយកសំណងនោះ មានសិទ្ធិជ្រើសរើសយកសំណងបណ្តោះអាសន្នដោយផ្អែកលើការខូចខាតកាលពីមុនដែលមានឯកសារបញ្ជាក់ ក្នុងអំឡុងពេលកំពុងរង់ចាំភស្តុតាងបញ្ជាក់ពីការងើបឡើងវិញនៃសេដ្ឋកិច្ចនៅតំបន់ឆ្នេរ។</u>

a. ការខាតបង់ជាក់ស្តែងដែលមានឯកសារបញ្ជាក់: នៅពេលដែលអ្នកទាមទារសំណងបានបង្ហាញពីទំនាក់ទំនងផ្ទាល់ដែលភ្ជាប់ការខាតបង់ដែលនៅបន្តសម្រាប់ពេលអតីតកាល និងការខូចខាតនាពេលបច្ចុប្បន្នទៅនឹងការកំពប់ប្រេង អ្នកទាមទារសំណងដែលមានសិទ្ធិស្របច្បាប់នឹងបានទទួលសំណងសម្រាប់ការខូចខាតដែលមានឯកសារបញ្ជាក់ ហើយដែលបង្កដោយផ្ទាល់ពីការកំពប់ប្រេងភ្លាមៗក្នុងអំឡុងពេលក្រោយពីការកំពប់ប្រេងនៅថ្ងៃទី 20 ខែមេសា ឆ្នាំ2010 និងជាកាលបរិច្ឆេទដាក់បណ្តឹងទាមទារបណ្តោះអាសន្ន ឬ ចុងក្រោយទៅ GCCF ("អំឡុងពេលខាតបង់")។ ការគណនាការខាតបង់ជាក់ស្តែងដែលមានឯកសារបញ្ជាក់នឹងផ្អែកទៅលើការប្រៀបធៀបប្រាក់ចំណូលក្នុងឆ្នាំមុនៗសម្រាប់ខែដូចគ្នា (ឧទាហរណ៍ ការប្រៀបធៀបប្រាក់ចំណូលដែលរកបានៅក្នុងឆ្នាំ 2008- 2009 ឬ ការប្រៀបធៀបតាមប្រវត្តិសមស្របដទៃទៀតដែលចាត់ទុកថា មានការពាក់ព័ន្ធខ្លាំងបំផុតទៅនឹងបទពិសោធន៍របស់អ្នកប្តឹងទាមទារ)។ ក្នុងករណីបែបនេះ ការខាតបង់ជាក់ស្តែងរបស់អ្នកទាមទារនឹងត្រូវបានកំណត់ដោយយកភាពខុសគ្នារវាងប្រាក់ចំណូលរបស់អ្នកទាមទារក្នុងអំឡុងពេលនៃការខាតបង់ និងអំឡុងពេលនៃការប្រៀបធៀប (ក្នុងករណីភាគច្រើនបំផុត គឺ ឆ្នាំ2008 - 2009) មកទល់នឹងការខាតបង់ជាក់ស្តែងរបស់អ្នកទាមទារ។

បណ្តឹងទាមទារនីមួយៗនឹងត្រូវបានត្រួតពិនិត្យ និងវាយតម្លៃទៅតាមខ្លឹងសារផ្ទាល់ និងកាលៈទេសៈជាក់លាក់របស់វា ដូចជា ទំនោរអាជីវកម្មរហូតមកដល់ពេលកំពប់ប្រេងពីខែ មករា ដល់ខែ មេសា ឆ្នាំ2010។ ឧទាហរណ៍ បណ្តឹងទាមទារអាជីវកម្មសម្រាប់ក្រុមហ៊ុន "ទើបចាប់ផ្តើ" ដែលបានប្រមើលឃើញនូវការបង្កើនប្រាក់ចំណូលនៅក្នុងឆ្នាំ2010 នឹងស្ថិតនៅក្រោមវិធីសាស្ត្រផ្សេងៗគ្នា។ អាជីវកម្មដែលទើបចាប់ផ្តើមបង្ហាញនូវបញ្ហាប្រឈមខ្លាំងក្នុងការព្យាករណ៍ដោយសារតែទិន្នន័យហិរញ្ញវត្ថុដែលមានពីពេលមុនមាននៅកម្រិត។ នៅក្នុងការវាស់ស្ទង់ពីការខាតបង់សម្រាប់អាជីវកម្មដែលទើបចាប់ផ្តើម GCCF នឹងពិចារណាលើផែនការអាជីវកម្ម ការប្រៀបធៀបទីផ្សារ ទិន្នន័យហិរញ្ញវត្ថុមុន និងក្រោយពេលខាតបង់ ថ្លៃចំណាយសម្រាប់បើក ទំនោរឧស្សាហកម្ម និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត។ ការផ្តោតការយកចិត្តទុកដាក់ពិសេសផងដែរ ទៅលើអាជីវកម្មទាំងឡាយដែលបិទទ្វារដោយសារលទ្ធផលផ្ទាល់នៃការកំពប់ប្រេង។

មានការទទួលបាននូវមតិយោបល់ជាច្រើនពាក់ព័ន្ធនឹងការខាតបង់ភាគរយនៃប្រាក់ចំណូល ("LOI") សម្រាប់អាជីវកម្ម។ LOI ដែលប្រើសម្រាប់អាជីវកម្មនីមួយៗ ត្រូវបានគណនាជាទូទៅដោយផ្អែកលើព័ត៌មានហិរញ្ញវត្ថុរបស់អាជីវកម្មជាក់លាក់។ ដោយឡែក ភាគរយនៃ LOI ដែលបានគណនាសម្រាប់អាជីវកម្មនីមួយ គឺផ្អែកលើផលកម្រៃប្រចាំឆ្នាំមុនពេលខាតបង់ផ្ទាល់របស់អាជីវកម្មនោះ (ឧ. ឆ្នាំ2009) និងរបាយការណ៍ស្តីពីការខាតបង់ ឬ ការបង់ពន្ធ ដោយផ្អែកលើសំណុំឯកសារដែលផ្តល់ឱ្យដោយអ្នកទាមទារសំណង។ ភាគរយនៃ LOI បានកែសម្រួលប្រាក់ចំណូលដែលខាតបង់រដើម្បីឆ្លុះបញ្ចាំងពីចំណាយដែលបានសន្សំ ឬ បញ្ឈប់ សម្រាប់អាជីវកម្មនោះ។ ចំណាយដែលត្រូវបានចាត់ទុកដោយឡែកថា ត្រូវបានសន្សំ ឬ បញ្ឈប់ទាំងស្រុង ឬ ជាផ្នែកបណ្តាលមកពីការលក់ដែលខាតបង់ ដូចជា ថ្លៃចំណាយលើទំនិញដែលបានលក់ កម្រៃជើងសារ ប្រាក់ខែ និងទឹកភ្លើង។

b. ការផ្តល់សំណងបណ្តោះអាសន្ន: អ្នកទាមទារសំណងដែលមិនបានត្រៀមខ្លួនទទួលយកសំណងចុងក្រោយអាចបន្តដាក់ពាក្យទាមទារសំណងបណ្តោះអាសន្នបានសម្រាប់ការខូចខាតពីមុនដែលមានឯកសារបញ្ជាក់។ បណ្តឹងទាមទារសំណងបណ្តោះអាសន្នអាចនឹងដាក់នៅក្នុងអំឡុងត្រីមាសនីមួយៗតាមឆ្នាំប្រតិទិន។ ចំពោះអ្នកទាមទារសំណងភាគច្រើន ភាគច្រើននៃការខាតបង់ដែលមានឯកសាររបស់ពួកគាត់ បានសងសំណងរួចរាល់ដោយក្រុមហ៊ុន BP និងកម្មវិធីផ្តល់សំណងបន្ទាន់ជាមុនរបស់ GCCF រួចហើយ។ ចំនួនប្រាក់សរុបដែលទទួលបានកាលពីមុនដោយអ្នកទាមទារសំណងខូចខាតបណ្តាលមកពីការកំពប់ប្រេងពីក្រុមហ៊ុន BP និង GCCF នឹងត្រូវបានកាត់បន្ថយពីការផ្តល់សំណងបណ្តោះអាសន្ន។

c. ការគណនាពីការខាតបង់នាពេលអនាគត: ការគណនាពីការខាតបង់នាពេលអនាគត គឺផ្អែកទៅលើការខាតបង់ជាងក់ស្តែងដែលទទួលរងភ្លាមៗបន្ទាប់ពីអំឡុងពេលនៃការខ្ចប់ប្រេងនៅថ្ងៃទី20 ខែមេសា ឆ្នាំ2010 ដល់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2010។ GCCF នឹងប្រើប្រាស់ការខាតបង់នៅឆ្នាំ2010ដែលមានឯកសារជាក់ស្តែង និងកត្តាងើបឡើងវិញនាពេលអនាគត ដោយបានប្រមើលមើលពីការងើបឡើងវិញបន្តិចម្តងៗនៃសេដ្ឋកិច្ច ដើម្បីប៉ាន់ស្មានពីការខាតបង់នាពេលអនាគតពាក់ព័ន្ធនឹងការហៀរប្រេងនេះ។ បទពិសោធន៍ជាមួយនឹងព្រឹត្តិការណ៍ដែលមិនបានដឹងមុន និងមានមហន្តរាយដទៃទៀតបានបង្ហាញថា ចំពោះអាជីវកម្មទាំងអស់ ក្រៅពីការវិនិយោគងារ និងការកែច្នៃងារ ការងើបឡើងវិញនឹងបន្តនៅក្នុងឆ្នាំ2011 ដោយការងើបឡើងវិញពេញលេញរំពឹងថាអាចនឹងមាននៅក្នុងឆ្នាំ 2012។ ការងើបឡើងវិញក្នុងរយៈពេលនេះនឹងនាំឱ្យមានការផ្តល់សំណងចុងក្រោយចំនួនទ្វេដងសម្រាប់ការខាតបង់ដែលមានឯកសារជាក់ស្តែងនៅក្នុងឆ្នាំ2010។ បន្ទាប់ពិនិត្យមើលមតិយោបល់ ដែលទទួលបានទាំងអស់ GCCF នៅបន្តមានជំនឿថា កត្តាងើបឡើងវិញនាពេលអនាគតចំនួន 1,0 (ពីរដងនៃការខាតបង់ដែលមានឯកសារជាក់ស្តែង) នៅក្នុងឆ្នាំ2010 មានភាពត្រឹមត្រូវ និងសមហេតុផល។ អ្នកទាមទារសំណងដែលមិនឯកភាពលើសេចក្តីសន្និដ្ឋាននេះ ត្រូវបានជំរុញឱ្យជ្រើសរើសការផ្តល់សំណងបណ្តោះអាសន្នសម្រាប់ការខូចខាតពីអតីតកាល។

មានការទទួលបានមតិយោបល់ជាច្រើនពាក់ព័ន្ធនឹងការគណនាការខាតបង់នាពេលអនាគតរបស់ GCCF ដែលផ្អែកលើការខាតបង់ជាក់ស្តែងដែទទួលរងភ្លាមៗក្នុងអំឡុងពេលបន្ទាប់ពីការកំពប់ប្រេង នៅថ្ងៃទី 20 ខែមេសា ឆ្នាំ2010 ដល់ខែធ្នូ ឆ្នាំ2010។ មតិយោបល់ទាំងនេះបានបញ្ជាក់ថា ការបង្កើនទ្វេដងនៃរយៈពេលខាតបង់ចំនួន 8ខែ ដែលស្នើឡើងរបស់ GCCF នឹងសងអ្នកទាមទារតែរយៈពេលខាតបង់ 16ខែប៉ុណ្ណោះ និងបានលើកឡើងថា វានឹងកាន់តែមានសមធម៌ដែលត្រូវប្រើរយៈ12ខែជំនួសវិញ។ មតិយោបល់ទាំងនេះបានធ្វើឱ្យមានការយល់ច្រឡំលើការគណនាការខាតបង់នាពេលអនាគតដែលស្នើឡើងសម្រាប់ហេតុផលទាំងឡាយដូចខាងក្រោម:

- ប្រសិនបើរយៈពេលខាតបង់ 12ខែត្រូវបានប្រើប្រាស់ដើម្បីគណនាការខាតបង់នាពេលអនាគតក្រៅពីរយៈ8ខែ នោះចំនួនសំណងចុងក្រោយសរុបនឹងមិនមានការផ្លាស់ប្តូរឡើយ។ នេះគឺដោយសារតែកត្តាងើបឡើងវិញនាពេលអនាគតត្រូវបានបង្កើតឡើងដើម្បីផ្តល់សំណងដល់អ្នកទាមទារសំណងចំពោះការខាតបង់ជាក់ស្តែងដែលបានប៉ាន់ស្មាននៅក្នុងរយៈពេល 4ខែ "ដែលបាត់បង់"។
- ប្រសិនបើ GCCF ប្រើរយៈពេលខាតបង់មួយឆ្នាំពេញ (ខែឧសភា ឆ្នាំ2010 ដល់ខែមេសា ឆ្នាំ2011) នោះនឹងគ្មានការផ្តល់សំណងចុងក្រោយឡើយរហូតដល់ខែឧសភា ឆ្នាំ2011 បើរហ័សបំផុត។

សម្រាប់ការឆ្លើយតបពិស្តារចំពោះមតិយោបល់នានាអំពីការគណនាលើការខាតបង់នាពេលអនាគត សូមមើលសេចក្តីពន្យល់ដែលមានភ្ជាប់មកជាមួយរបស់ ARPC ជាក្រុមហ៊ុនជំនាញផ្នែកសេដ្ឋកិច្ចវិទូដែលត្រូវបានជួលទុកជាមុនដោយ GCCF។ (សូមមើលឯកសារភ្ជាប់ B សម្រាប់ " ការឆ្លើយតបទៅនឹងមតិយោបល់អំពីការជៀសវាង និងការគណនាអំពីការខូចខាងខាតនាពេលអនាគត"។

d. អ្នកជំនាញមួយចំនួនបានគិតថា ក្រុមបុគ្គល និងអាជីវកម្មនានាដែលពាក់ព័ន្ធនឹងការប្រមូលផល និងការកែច្នៃអយស្ទ័រដែលរងការបំផ្លិចបំផ្លាញដែលបណ្តាលមកពីការហៀរប្រេង ឬ បណ្តាលមកពីការបំឡែងទឹកសាបដែលហូរចូលក្នុងឈូងសមុទ្រដែលកំពុងមានប្រតិកម្មជាមួយនឹងការហៀរប្រេងនេះ អាចនឹងត្រូវការពេលវេលាសម្រាប់ការងើបឡើងវិញយូរជាងរយៈពេលដែលធ្លាប់ជួបប្រទះដោយអ្នកទាមទារសំណងដទៃៗទៀត ដូច្នេះហើយ សំណងចុងក្រោយទៅអ្នកទាមទារទាំងនោះ នឹងមានចំនួនស្មើនឹងបួនដងនៃការខាតបង់ដែលសំអាងលើឯកសារជាក់ស្តែងក្នុងឆ្នាំ2010។

5. សម្រាប់អ្នកទាមទារសំណងដែលសំអាងលើឯកសារជាក់ស្តែងក្នុងឆ្នាំ2010 ដែលមានចំនួនទឹកប្រាក់ស្មើនឹង 500 000 ដុល្លារអាមេរិក ឬ លើសពីនេះ GCCF នឹងមិនអនុវត្តដោយស្វ័យប្រវត្តិនូវកត្តាងើបឡើងវិញនាពេលអនាគតឡើយចំពោះការខាតបង់សរុបជាក់ស្តែងក្នុងឆ្នាំ2010 របស់អ្នកទាមទារសំណង។ ការគណនាសម្រាប់សំណងចុងក្រោយសម្រាប់អ្នកទាមទារសំណងទាំងនេះនឹងត្រូវកំណត់ដោយឈរលើមូលដ្ឋានជាបុគ្គលបន្ទាប់ពីការវិភាគលើយោបល់ពីអ្នកទាមទារក៏ដូចជាអ្នកជំនាញផ្សេងៗ។ ការផ្តល់សំណងចុងក្រោយនឹងសម្រាប់ការខាតបង់ដែលសំអាងលើឯកសារជាក់ស្តែងនៅក្នុងឆ្នាំ2010 និងចំនួនទឹកប្រាក់បន្ថែមដើម្បីទូទាត់សងសម្រាប់ការងើបឡើងវិញ និងហានិភ័យនៃការខាតបង់នាពេលអនាគតដែលអាចកើតមាន។

6. សរុបមក ចំពោះអ្នកទាមទារសំណងដែលមានឯកសារបញ្ជាក់ និងធ្វើការបញ្ជាក់អំពីការខាតបង់ហិរញ្ញវត្ថុ ដោយសារការកំពប់ប្រេងនោះ នឹងត្រូវបានទូទាត់ប្រាក់ជូនស្មើនឹង ចំនួនពីរដង នៃការខាតបង់កាលពីឆ្នាំ2010ដែលមានឯកសារបញ្ជាក់ជាក់ស្តែងដែលបណ្តាលមកពីការកំពប់ប្រេងដើម្បីសងការខូចខាតទាំងអស់ពីមុន និងការខាតបង់ដែលរំពឹងទុកនាពេលអាគត (លើកលែងតែចំពោះករណីដូចមានចែង គឺសម្រាប់អ្នកទាមទារសំណងដែលរងការខាតបង់ក្នុងឆ្នាំ2010 ដែលមានចំនួនទឹកប្រាក់ស្មើនឹង 500 000 ដុល្លារអាមរិក ឬ លើស ពីនេះប៉ុណ្ណោះ)។ បណ្តាអ្នកប្រមូលផលអយស្ទ័រដែលបានប្រើឯកសារបញ្ជាក់អះអាង និងបានបញ្ជាក់អំពីការខាតបង់ហិរញ្ញវត្ថុដែលបណ្តាលមកពីការកំពប់ប្រេងនោះ នឹងត្រូវបានទូទាត់ប្រាក់ជូនស្មើនឹងចំនួន បួនដងនៃការខាតបង់កាលពីឆ្នាំ2010ដែលមានឯកសារអះអាងជាក់ស្តែងដែលបណ្តាលមកពីការកំពប់ប្រេងដើម្បីសងការខូចខាតទាំងអស់ពីមុន និងការខាតបង់ដែលរំពឹងទុកនាពេលអាគត។ បន្ទាប់ពីការត្រួតពិនិត្យលើមតិយោបល់ជាសាធារណៈដែលទទួលបានទាំងអស់រួច GCCF បានគណនាឃើញថា កត្តាងើបឡើងវិញនាពេល អនាគតនៃការខាតបង់ក្នុងឆ្នាំ2010 ដែលមានឯកសារអះអាងជាក់ស្តែងចំនួនបួនដងនោះ ក៏នឹងត្រូវបានអនុវត្តផងដែរចំពោះការខាតបង់ក្នុងឆ្នាំ2010 ដែលមានឯកសារបញ្ជាក់អះអាងជាក់ស្តែងសម្រាប់អ្នកកែច្នៃ អយស្ទ័រ។ (សម្រាប់អ្នកទាមទារសំណងទាំងអស់ ការផ្តល់សំណងនឹងត្រូវបានកាត់បន្ថយតាមរយៈសំណងថ្លៃខូចខាតដែលបានទទួលរួចរាល់ក្នុងការសងសំណងបន្ទាន់ពីក្រុមហ៊ុន BP ការសងសំណងបន្ទាន់ និងការសងសំណងបណ្តោះអាសន្នដែលទទួលបានពី GCCF និងការទូទាត់សងផ្សេងៗទៀត)។ ប្រសិនបើមានអ្នកទាមទារសំណងណាម្នាក់គិតថា ឈូងសមុទ្រនាពេលខាងមុខ នៅតែបន្តមានសមភាពមិនច្បាស់លាស់ ហើយខ្លួនមិនទាន់រៀបចំឯកសារប្តឹងទាមទារសំណងចុងក្រោយនោះ អ្នកទាមទារសំណងនោះបន្តប្តឹងទាមទារសំណងបណ្តោះអាសន្នបាន ដោយបង្ហាញពីការខូចខាតដែលកំពុងបន្តកើតមានពាក់ព័ន្ធនឹងការកំពប់ប្រេងនេះជាមួយនឹង GCCF។ អ្នកទាមទារសំណងណាដែលប្តឹងទាមទារសំណងបណ្តោះអាសន្ន មិនចាំបាច់ចុះហត្ថលេខាលើឯកសាររួចបន្ទុកឡើយ។ អ្នកទាមទារសំណងណាដែលប្តឹងទាមទារសំណងបណ្តោះអាសន្ន មិនចាំបាច់ចុះហត្ថលេខាលើឯកសាររួចបន្ទុកឡើយ។

7. សំណងចុងក្រោយ ឬ សំណងបណ្តោះអាសន្ន: GCCF នឹងសងប្រាក់ទៅបុគ្គល ឬ អាជីវកម្មដែលមានសិទ្ធិទាំងជាសំណងចុងក្រោយ និងសំណងបណ្តោះអាសន្ន តាមការស្នើសុំរបស់អ្នកទាមទារ។ កត្តាងើបឡើងវិញសម្រាប់ពេលអនាគត ដូចបានកំណត់ដោយ GCCF អាចនឹងមានការឈានឆ្ពោះទៅមុខ ខណៈដែលអាចរកបានព័ត៌មានបន្ថែមអំពីអានាគតនៃសេដ្ឋកិច្ចនៅតំបន់ឆ្នេរនៃឈូងសមុទ្រ។ ដូច្នេះ វាអាចមានលទ្ធភាពកើតមានយ៉ាងទូលំទូលាយ ចំពោះការដែលថា កត្តាងើបឡើងវិញនាពេលអនាគតសម្រាប់កំណត់លើផលប៉ះពាល់នាពេលអនាគតពីការកំពប់ប្រេងនៅក្នុងឈូងសមុទ្រអាចនឹងកើនឡើង ឬ ធ្លាក់ចុះនៅពេលដែលអាចរកបានព័ត៌មានបន្ថែមទៀត។ អ្នកទាមទារសំណងអាចនឹងពិចារណាលើលទ្ធភាពមួយនេះដើម្បីសម្រេចថា តើគួរដាក់ពាក្យប្តឹងទាមទារសំណងចុងក្រោយតែម្តង ឬ ប្តឹងទាមទារសំណងបណ្តោះអាសន្ន។

8. <u>**ចំពោះអ្នកទាមទារសំណងដែលបានដាក់ពាក្យប្តឹងទាមទារសំណងចុងក្រោយដោយប្រើសំណុំឯកសារឆ្នាំ 2010 មិនពេញលេញនោះ ខាង GCCF នឹងធ្វើការកំណត់ និងគណនាលើការទាមទារនេះដោយផ្អែកលើការខាតបង់ក្នុងឆ្នាំ2010ជាក់ស្តែងដែលមានឯកសារសំអាងដែលបានដាក់**</u>។ អ្នកទាមទារសំណងនឹងមានជម្រើសក្នុងការទទួលយកសំណងចុងក្រោយ ដោយផ្អែកលើសំណុំឯកសារអំពីការខាតបង់ជាក់ស្តែងក្នុងឆ្នាំ 2010 ដែលបានដាក់បញ្ជូនមកដែលមានសម្រាប់ GCCF សម្រាប់ធ្វើការកំណត់ និងការគណនា ឬ ស្នើសុំការវាយតម្លៃសារជាថ្មីលើការទាមទារសំណងចុងក្រោយបន្ទាប់ពីខ្លួនបានដាក់ឯកសារបន្ថែមស្តីពីការខាតបង់ក្នុងឆ្នាំ2010។

**ចំនួនទឹកប្រាក់សំណងចុងក្រោយរបស់អ្នកទាមទារម្នាក់ៗនឹង:**

**(1) មានចំនួនពីរដងនៃការខាតបង់ដែលមានឯកសារអះអាងជាក់ស្តែងក្នុងឆ្នាំ 2010 របស់អ្នកទាមទារសំណងដែលមានសិទ្ធិ (លើកលែងតែចំពោះអ្នកទាមទារណាដែលមានទំហំនៃការខាតបង់ក្នុងឆ្នាំ 2010 លើសពីចំនួនទឹកប្រាក់ 500 000 ដុល្លារ) មានចំនួន បួនដងនៃការខាតបង់ដែលមានឯកសារសំអាងជាក់ស្តែងក្នុងឆ្នាំ2010 សម្រាប់ការខាតបង់ដែលមានឯកសារសំអាងជាក់ស្តែងក្នុងឆ្នាំ2010 របស់អ្នកប្រមូលផល និងអ្នកកែច្នៃអយស្ទ័រ ឬ**

**(2) ការខាតបង់ដែលមានឯកសារសំអាងជាក់ស្តែងសរុបរហូតដល់កាលបរិច្ឆេទនៃការដាក់ពាក្យប្តឹងទារសំណងចុងក្រោយ។**

IV. ការសំអាងលើឯកសារ/ការបញ្ជាក់ពីភស្តុតាង

បើទោះបីជាភាគច្រើននៃរយៈពេលសម្រាប់ការផ្តល់មតិយោបល់ជាសាធារណៈត្រូវបានចំណាយទៅលើបញ្ហានានាពាក់ព័ន្ធនឹងវិធីសាស្ត្រគណនាដើម្បីកំណត់សំណងចុងក្រោយក៏ដោយ ការសំខាន់គឺថា ពល់អ្នកទាមទារទាំងអស់ដែលស្វែងរកសំណងចុងក្រោយ ឬ សំណងបណ្តោះអាសន្ន ផ្តោតការយកចិត្តទុកដាក់របស់ខ្លួនទៅលើបញ្ហាក្នុងការប្រើឯកសារបញ្ជាក់អះអាង និងសមត្ថភាពរបស់អ្នកទាមទារសំណងម្នាក់ៗដើម្បីបញ្ជាក់ពីការខូចខាតរបស់ខ្លួនដែលបានកើតមានបណ្តាលមកពីការកំពប់ប្រេងនេះ។

**វាជាការចាំបាច់ដែលថា អ្នកទាមទារសំណងទាំងអស់ត្រូវតែបញ្ជាក់ឱ្យច្បាស់លាស់ អំពីការទាមទារសំណងរបស់ខ្លួនតាមរយៈការផ្តល់ឱ្យ GCCF នូវសំណុំឯកសារគ្រប់គ្រាន់ដែលគាំទ្រដល់ការទាមទារសំណង់សម្រាប់ការខូចខាត។ (សូមមើល ឯកសារភ្ជាប់ A C និង D សម្រាប់ព័ត៌មានដើម្បីជួយដល់បណ្តាអ្នកទាមទារសំណងទាំងអស់ឱ្យបានយល់អំពីការធ្វើតេស្តហិរញ្ញវត្ថុដែលប្រើប្រាស់ដោយ GCCF ក្នុងការអះអាងពីការខូចខាត និងសំណុំឯកសារដែលត្រូវការ និងភស្តុតាងចាំបាច់ដើម្បីបញ្ជាក់អះអាងអំពីទំនាក់ទំនងមួយរវាងការខាតបង់ និងការកំពប់ប្រេង)។**

**GCCF សូមណែនាំដល់អ្នកទាមទារសំណងទាំងអស់ថា សំណុំឯកសារទាំងសម្រាប់ការទាមទារសំណងចុងក្រោយ និងសំណងបណ្តោះអាសន្ន មានភាពខ្វះចន្លោះក្នុងករណីភាគច្រើន។ ការណ៏នេះគឺជារឿងពិតជាក់ស្តែងសម្រាប់សំណុំឯកសារគាំទ្រឆ្នាំ 2010 ។ មកទល់នឹងកាលបរិច្ឆេទនៃសេចក្តីជូនដំណឹងនេះ មានអ្នកទាមទារសំ ណងតិចជាង 17% ប៉ុណ្ណោះ ដែលបានដាក់សំណុំឯកសារឆ្នាំ2010 ពេញលេញ។ របាយការណ៍មិនពេញលេញនឹងធ្វើឱ្យយឺតយ៉ាវដល់ការត្រួតពិនិត្យឡើងវិញលើការទាមទារសំណងនេះ បង្កផលប៉ះពាល់ដល់ការគណនាលើការខូចខាត និងអាចនាំទៅដល់ការបដិសេធន៍ការទាមទារទៀតផង។**

1. ដូចដែលមានចង្អុលបង្ហាញយ៉ាងច្បាស់លាស់ពីខាងដើមបំផុតនៃកម្មវិធីសងសងសំណងបន្ទាន់នោះ តម្រូវការសំណុំឯកសារដើម្បីទទួលបានសំណងចុងក្រោយ និងសំណងបណ្តោះអាសន្ន គឺមានសភាពហ្មត់ចត់ និងជាក់លាក់ជាងតម្រូវការឯកសារតិចតួចដែលជះឥទ្ធិពលដល់ការគ្រប់គ្រងកម្មវិធីសងប្រាក់សំណងបន្ទាន់។ អ្នកទាមទារសំណងម្នាក់ៗ ត្រូវបានតម្រូវឱ្យអះអាងពីការខាតបង់ថវិកាជាក់ស្តែង និងទំនាក់ទំនងរវាងការខាតបង់ និងការកំពប់ប្រេង។

2. ការទាមទារសំណងនីមួយៗ គឺផ្អែកលើស្ថានភាពស័ក្តិសមរបស់វាផ្ទាល់ ហើយ GCCF នឹងវាយតម្លៃលើការគោរពតាមនីមួយៗដើម្បីកំណត់ថា តើការខាតបង់ត្រូវបានបង្កឡើងដោយការកំពប់ប្រេងដែរ ឬយ៉ាងណា។ នៅពេលដែលវាយតម្លៃលើការទាមទារសំណងថ្លៃខូចខាតនីមួយៗនោះ GCCF នឹងធ្វើការសន្មតទុកជាមុនខ្លះថា ការខាតបង់ទាំងនោះត្រូវបានបង្កឡើងដោយការកំពប់ប្រេង ដោយផ្អែកទៅលើភាពស្ថិតនៅជិតរបស់អ្នកទាមទារសំណងទៅនឹងតំបន់ឆ្នេរឈូងសមុទ្រ និងលក្ខណៈនៃសកម្មភាពអាជីវកម្មរបស់អ្នកទាមទារសំណង។

3. គំរូប្លង់ខាងក្រោមសម្រាប់ការចង្អុលបង្ហាញភស្តុតាងដែលតម្រូវដោយ GCCF ដើម្បីធ្វើការបញ្ជាក់អំពីការទាមទារសំណងដែលអាចសងបាន គឺអាស្រ័យលើយោបល់របស់អ្នកជំនាញដែលត្រូវបានជូលទុកជាមុនដែលវាយតម្លៃអំពីលក្ខណៈប្រហាក់ប្រហែលនៃទំនាក់ទំនងមួយរវាយការកំពប់ប្រេង និងការទាមទារសំណងថ្លៃខូចខាត។ ប្លង់ទាំងឡាយខាងក្រោមនេះ គឺសម្រាប់តែជាការណែនាំប៉ុណ្ណោះ។

a. <u>ស្ថានភាពស្ថិតនៅជិតខាងរូបវន្តទៅនឹងទីតាំងកំពប់ប្រេង/កម្មករ និងអាជីវកម្មដែលអាស្រ័យដោយផ្ទាល់លើធនធាននានារបស់ឈូងសមុទ្រ៖</u> ទំនាក់ទំនងមួយទៅនឹងការកំពប់ប្រេង គឺមានភាពងាយស្រួលបំផុតក្នុងការបង្ហាញក្នុងករណីមួយចំនួនពាក់ព័ន្ធនឹងកម្មករ **អាជីវកម្មដែលពឹងពាក់អាស្រ័យផលដោយផ្ទាល់លើធនធាននានានៃឈូងសមុទ្រនេះ និងវិស័យទេសចរណ៍ ហើយស្ថិតនៅក្នុងទីផ្លាដែលស្ថិតនៅជិតតំបន់ឆ្នេរនៃឈូងសមុទ្រ ព្រមទាំងអ្នកទាមទារសំណងដែលត្រូវបានកំណត់រួចជាស្រេចថា មានសិទ្ធិសម្រាប់ការទទួលបានសំណងបន្ទាន់បពី GCCF ។** ឧទាហរណ៍ដូចជា អ្នកនេសាទ អ្នកចិញ្ចឹមបង្គា អ្នកប្រមូល អយស្ទ័រ កាពីទែនទូក អ្នកកែច្នៃអាហារសមុទ្រក៏ដូចជាសកម្មភាពអាជីវកម្មដែលពឹងផ្អែកខ្លាំងលើវិស័យទេសចរណ៍ នៅក្នុងទីផ្លាស្ថិតនៅក្បែរ ដូចជាផែសម្រាប់ឈប់សម្រាក សណ្ឋាគារ ភោជនីយដ្ឋាន និងទីតាំងជួលផ្សេងៗដែលស្ថិតនៅលើឆ្នេរនៃតំបន់ឆ្នេររបស់ឈូងសមុទ្រនេះ។ ក្នុងករណីទាំងនេះ ក៏ដូចជាក្នុងការណីផ្សេងទៀតដែលអ្នកទាមទារសំណងបានដាក់បញ្ជូនសំណុំឯកសារគ្រប់គ្រាន់រួចជាស្រេចដើម្បីទទួលបានសំណងបន្ទាន់ នោះប្រតិបាទន៍នៃព័ត៌មាន និងទិន្នន័យអំពីហិរញ្ញវត្ថុគ្រប់គ្រាន់ដែលប្រៀបធៀបគ្នាអំពីប្រាក់បៀវត្សរ៍ និងចំណូលនៅពេលមុន និងបន្ទាប់ពីការកើតមានការកំពប់ប្រេងនោះ ជាធម្មតានឹងត្រូវបានគេគិតថា មានលក្ខណៈគ្រប់គ្រាន់ដើម្បីដាក់ពាក្យបណ្តឹងទាមទារសំណងនេះ។ **ប៉ុន្តែទោះជាយ៉ាងណា ថ្វីបើមាន ការទាមទារប្រភេទនេះក៏ដោយ ក៏បច្ចុប្បន្ននេះ GCCF បានរកឃើញថា បណ្តឹងទាមទារដែលបានដាក់ភាគច្រើនគឺមានការខ្វះចន្លោះយ៉ាងខ្លាំងនូវសំណុំឯកសារដែលប្រៀបធៀបប្រាក់បៀវត្សរ៍ និងចំណូលនៅពេលមុន និងក្រោយការកើតមានការកំពប់ប្រេង និងសំណុំឯកសារហិរញ្ញវត្ថុឆ្នាំ 2010 ដែលពេញលេញមួយ។**

b. <u>គម្លាតរូបវន្តពីទីតាំងកំពប់ប្រេង/កម្មករ និងអាជីវកម្មដែលមិនសូវពឹងផ្អែកខ្លាំងលើធនធានឈូងសមុទ្រ៖</u> សម្រាប់អាជីវកម្ម និងបុគ្គលណាដែលមិនស្ថិតក្នុងបរិវេណក្បែរនឹងឈូងសមុទ្រនេះ ប៉ុន្តែមានដំណើរការអាជីវកម្មនៅក្នុងស្រុកនានាដែលស្ថិតនៅក្បែរឈូងសមុទ្រដែលមិនសូវមានការប៉ះពាល់ខ្លាំងពីការរំខានដល់វិស័យទេសចរណ៍ ការប្រមូលផលអាហារសមុទ្រនៅតាមតំបន់ឆ្នេរនៃឈូងសមុទ្រនោះ តម្រូវឱ្យមានសំណុំឯកសារកាន់តែជាក់លាក់ជាងនេះ។ GCCF ផ្អែកការសន្និដ្ឋាននេះទៅតាមទស្សនៈរបស់អ្នកជំនាញដែលការគូសបញ្ជាក់បន្ថែមមានភាពចាំបាច់សម្រាប់ការសន្និដ្ឋានថាខាតបង់ដែលបណ្តាលមកពីការកំពប់ប្រេង ចម្ងាយកាន់តែឆ្ងាយដែលទីតាំងអាជីវកម្មស្ថិតពីបរិវេណក្បែរកន្លែងកំពប់ប្រេង ឬ ភាពដែលមិនសូវពឹងផ្អែកខ្លាំងនៃអាជីវកម្មទៅលើធនធាននៃឈូងសមុទ្រ។ ក្នុងករណីបែបនេះ GCCF សម្រេចយកតាមអនុសាសន៍របស់អ្នកជំនាញដែលអ្នកទាមទារសំណងអះអាងថា "និន្នាការវិជ្ជមាន" របស់ខ្លួនចំពោះការបាត់បង់ប្រាក់បៀវត្សរ៍ ឬ ប្រាក់ចំណេញអំឡុងពេលមុនបន្តិច នៃពេលមានការការកំពប់ប្រេងដែលត្រូវបានរំខានដោយឧបទ្ទវហេតុDeepwater Horizon incident។ **ការប្រៀបធៀបអំពីភាពខុសគ្នានៃប្រាក់បៀវត្សរ៍/ប្រាក់ចំណូលនៅមុន និងក្រោយការកំពប់ប្រេងអាចនឹងមានមិនគ្រប់គ្រាន់។ អ្នកទាមទារសំណងដែលស្ថិតក្នុងការទាមទារប្រភេទនេះនឹងទទួលបាននូវសំណុំឯកសារតាមរយៈការរៀបរាប់អំពីការខាតបង់ដោយការប្រើប្រាស់ការធ្វើតេស្តហិរញ្ញវត្ថុដែលវិភាគលើការអនុវត្តហិរញ្ញវត្ថុដែលពាក់ព័ន្ធនៅក្នុងរយៈពេលមុនបន្តិច និងក្រោយបន្តិចនៃការកើតមានការកំពប់ប្រេង។** ឯកសារភ្ជាប់ C មានបរិយាយអំពីការធ្វើតេស្តហិរញ្ញវត្ថុដែល GCCF អាចនឹងប្រើប្រាស់ដើម្បីបកស្រាយថាតើមានការខូចខាតបណ្តាលមកពីការកំពប់ប្រេង ឬ យ៉ាងណា និងសំណុំឯកសារដែលត្រូវការ។

c. <u>អ្នកទាមទារសំណងដទៃទៀតទាំងអស់៖</u> GCCF បានទទួលបណ្តឹងទាមទារសំណងពីអ្នកទាមទាមសំណងដែលរស់នៅក្រៅរដ្ឋក្នុងតំបន់ឈូងសមុទ្រ បណ្តឹងទាមទារសំណងពីក្រុមហ៊ុនអាជីវកម្មដែលមានទីតាំងស្ថិតនៅជាច្រើនម៉ាយល៍ពីតំបន់កំពប់ប្រេង និងបណ្តឹងទាមទារសំណងពីបណ្តាអាជីវកម្មនានាដែលមិនមានការពឹងផ្អែកដោយផ្ទាល់លើធនធាននៃឈូងសមុទ្រនៃដូចជា ទណ្ឌពេទ្យ បសុពេទ្យ និងគ្រូពេទ្យម៉ាស្សា។ ភាគច្រើននៃការទាមទារសំណងទាំងនេះកើតចេញពីសកម្មភាពនានាដែលពឹងផ្អែកភាគច្រើនលើស្ថានភាពសេដ្ឋកិច្ចទូទៅជាងលើវិស័យទេសចរណ៍ ការប្រមូលផលអាហារសមុទ្រ នៅលើតំបន់ឆ្នេរនៃឈូងសមុទ្រ។ ក្នុងករណីទាំងនេះ ( ដែលមានចំនួនរាប់ពាន់ករណី) ប្រភេទដែលជាក់លាក់បំផុតនៃការបង្ហាញភស្តុតាងលើទំនាក់ទំនងដែលអាចកំណត់អត្តសញ្ញាណបានរវាងការខូចខាតដែលត្រូវបានអះអាង និងការកំពប់ប្រេងនឹងតម្រូវឱ្យមាន។ អ្នកទាមទារសំណងប្រភេទនេះអាចនឹងទទួលបានសំណងថ្លៃខូចខាតតាមរយៈការអះអាងអំពីការខាតបង់ ដោយឆ្លងកាត់ការធ្វើតេស្តហិរញ្ញវត្ថុដែលវិភាគលើការអនុវត្តហិរញ្ញវត្ថុក្នុងអំឡុងពេលមុនបន្តិច និងក្រោយបន្តិចនៃការកំពប់ប្រេង និងតាមរយៈការផ្តល់ជាភស្តុតាងដែលបញ្ជាក់អះអាងអំពីទំនាក់ទំនងរវាងការខាតបង់ និងការកំពប់ប្រេង។ ជាឧទាហរណ៍ អ្នកទាមទារសំណងអាចផ្តល់ជាសំណុំឯកសារនៃការបញ្ជាទិញទំនិញ ឬ សេវានានាដែលលក់ទៅឱ្យទីតាំងអាជីវកម្មនៅក្នុងតំបន់ឈូងសមុទ្រដែលត្រូវបានលុបចោល ការលក់ថេរក្នុងរយៈពេលពីរឆ្នាំមុន ឬ លើសពីនោះទៅឱ្យទីតាំងអាជីវកម្មនៅក្នុងតំបន់ឈូងសមុទ្រ ដែលមិនមានសភាព ដូចដើមដោយសារតែការហៀរប្រេង បំណុលអាក្រក់ដែលត្រូវបានលុបចេញពីបញ្ជី និងពាក់ព័ន្ធនឹងការខកខានមិនបានសងប្រាក់ដោយក្រុមហ៊ុនអាជីវកម្មនៅក្នុងតំបន់ឈូងសមុទ្រ ការខកខានចំពោះការរៀបចំ តាមកិច្ចសន្យាពាក់ព័ន្ធនឹងក្រុមហ៊ុនអាជីវកម្មក្នុងតំបន់ឈូងសមុទ្រដែលបង្កឱ្យមានការលក់ និងចំណូលធ្លាក់ចុះដែលអាចមើលឃើញ ការចំណាយ ឬ ថ្លៃដើមទិញទំនិញដែលមានការកើនឡើងដោយសារតែការមាន ឬ ការទទួលទំនិញនោះពីអ្នកលក់ដទៃទៀតក្រៅពីអាជីវកម្មក្នុងតំបន់ឈូងសមុទ្របែបបុរាណ ការបញ្ចប់ពីការងារដែលជាក់លាក់ ឬ ការកាត់បន្ថយប្រាក់បៀវត្សរ៍ដែលការបញ្ជាក់អះអាងពីនិយោជកថា បណ្តាលមកពីការកំពប់ប្រេង។ល។ ឧទាហរណ៍មួយចំនួននៃប្រភេទភស្តុតាងដែលអាចផ្សារភ្ជាប់ការខាតបង់របស់អ្នកទាមទារសំណងទៅនឹងការកំពប់ប្រេងនោះ មានបរិយាយនៅក្នុងឯកសារភ្ជាប់ A។ **ការផ្តល់ព័ត៌មានហិរញ្ញវត្ថុទូទៅអំពីការខាតបង់ដែលកើតមានក្នុងឆ្នាំ2010 បន្ទាប់ពីការកំពប់ប្រេងនោះ នឹងមិនមែនជាសំណុំឯកសារគ្រប់គ្រាន់សម្រាប់អ្នកទាមទារសំណងប្រភេទនេះឡើយ។ ផ្ទុយមកវិញ ភស្តុតាងនឹងតម្រូវឱ្យមានជាពិសេសដែលផ្សារភ្ជាប់រវាងការខាតបង់ដែលទទួលរង និងការកំពប់ប្រេង។**

អ្នកទាមទារសំណងត្រូវបានក្រើនរំលឹកថា ក្នុងករណីមិនមានឯកសារចាំបាច់ដែលបញ្ជាក់ពីការទាមទារសំណងជាចុងក្រោយ ឬ ជាការទាមទារសំណងបណ្តោះអាសន្នទេនោះ នឹងមានជម្រើជា "ការសងរហ័ស" ចំពោះអ្នកទាមទារណាដែលបានទទួលរួចមកហើយនូវការបង់ប្រាក់បន្ទាន់ដោយមិនចាំបាច់ធ្វើការដាក់សំណុំឯកសារបន្ថែមមកកាន់ GCCF ឡើយ។ ការសងរហ័សជាទឹកប្រាក់ 5 000 ដុល្លារ នឹងប្រគល់ជូនបុគ្គល

ហើយ 25 000 ដុល្លារ នឹងប្រគល់ជូនដល់អាជីវកម្ម។ **ការសងរហ័សតម្រូវឱ្យមានការប្រកាសពេញលេញមួយ។ មុនពេលទទួលយកការទូទាត់ណាមួយ ឬចុះហត្ថលេខាលើឯកសារឱ្យរួចបន្ទុកតាមសិទ្ធិស្របច្បាប់ អ្នកទាមទារសំណងមានសិទ្ធិប្រឹក្សាយោបល់ជាមួយនឹងមេធាវីតាមការជ្រើសរើសរបស់ខ្លួនបាន។ ជំនួយផ្នែកច្បាប់ឥតគិតថ្លៃគឺមានសម្រាប់អ្នកទាមទារសំណងណាដែលមិនមានលទ្ធភាពជួលមេធាវីខ្លួនឯងបាន។**

## V. តម្លាភាព និងសង្គតភាពដែលកាន់តែល្អប្រសើរ

ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យប្រសើរឡើងដល់តម្លាភាព និងសង្គតភាពដែលល្អប្រសើរបំផុតនៅក្នុងដំណើរការប្ដឹងទាមទារសំណងរបស់ GCCF នោះ GCCF កំពុងតែផ្ដួចផ្ដើមបង្កើតឡើងនូវវិធានការជាហូរហែដែលតាក់តែងឡើង ដើម្បីផ្ដល់ឱ្យអ្នកទាមទារសំណងនូវការទទួលបានយ៉ាងល្អប្រសើរបំផុតនូវព័ត៌មានស្ដីពីការទាមទារជាលក្ខណៈបុគ្គលរបស់ខ្លួន រួមមានស្ថានភាពនៃការទាមទារសំណង និងមូលហេតុសម្រាប់ការកំណត់ទាំងឡាយដែលធ្វើឡើងដោយ GCCF (ការទទួលយក ឬ ការច្រានចោលការទាមទារ ការគណនាសំណងថ្លៃខូចខាត និងមូលហេតុដែលពាក់ព័ន្ធ ។ល។) (សូមមើលឯកសារភ្ជាប់ E សម្រាប់លិខិតបង់ប្រាក់គំរូ និងការគណនាលើការវាយតម្លៃ)។ ពាក់ព័ន្ធជាមួយនឹងការចាប់ផ្ដើមនៃដំណើរការសងប្រាក់សំណងចុងក្រោយ និងការសងសំណងបណ្ដោះអាសន្ន GCCF សូមធ្វើការក្រើនរំលឹកដល់បណ្ដាអ្នកទាមទារសំណងទាំងឡាយដូចខាងក្រោមនេះ

1. បុគ្គលិក ក្នុងស្រុកបន្ថែមដែលជួលទុកដោយ GCCF ហើយពេលបច្ចុប្បន្ននេះកំពុងស្ថិតក្នុងទីតាំងការិយាល័យ សម្រាប់ទាមទារសំណងនៅទូទាំងតំបន់ឈូងសមុទ្រដើម្បីជួយដល់អ្នកទាមទារសំណងក្នុងការធានាចំពោះការទទួលបានព័តមានបន្ថែមអំពីលក្ខណៈនៃការទាមទាររបស់ខ្លួន និងក្នុងការលាតត្រដាងអំពីមូលហេតុផ្សេងៗសម្រាប់ការធ្វើសេចក្ដីសម្រេចលើការទាមទារនៃ GCCF ។ បុគ្គលិកក្នុងស្រុកទាំងនេះគឺជាអ្នករស់នៅក្នុងតំបន់នោះផ្ទាល់តែម្ដងដែលជាអ្នកស៊ាំជាមួយនឹងក្រុមហ៊ុនអាជីវកម្ម និងការងារតាមតំបន់ឆ្នេរនៃឈូងសមុទ្រនោះផ្ទាល់។ ពួកគេត្រូវមានវត្តមាននៅក្នុងតំបន់ឈូងសមុទ្រដើម្បីជួយដល់អ្នកទាមទារសំណងក្នុងការរៀបចំបែបបទទាមទារសំណងពី GCCF ។ រាល់បុគ្គលិកទាំងអស់នៅក្នុងការិយាល័យនៃទីតាំងទាមទារសំណង គឺជាអ្នកទទួលការបន្តរបស់ GCCF។ ក្រុមហ៊ុន BP បានផ្ដល់ថវិកាសម្រាប់ការចំណាយលើកិច្ចការរដ្ឋបាលរបស់ GCCF រួមទាំងសំណងថ្លៃខូចខាតសម្រាប់អ្នកទទួលការបន្តរបស់ GCCF ផងដែរ។

2. អ្នកទាមទារសំណង ក៏ត្រូវបានអញ្ជើញឱ្យស្វែងរកជំនួយជាគណនេយ្យករក្នុងស្រុក និងក្រុមហ៊ុនគណនេយ្យនានាផងដែរនៅក្នុងការរៀបចំ និងការដំណើរការទាមទារសំណងជាលក្ខណៈបុគ្គលរបស់ខ្លួន ឬសម្រាប់ការវាយតម្លៃលើការផ្ដល់សំណងចុងក្រោយ ឬ សំណងបណ្ដោះអាសន្នរបស់ GCCF ។ ក្រុមហ៊ុនគណនេយ្យទាំងនេះ <u>មិនមែន</u> ជាអ្នកទទួលការបន្តរបស់ GCCF មិនត្រូវបានជួលទុកដោយ GCCF មិនធ្វើការងារឱ្យ GCCF ឡើយ គឺពួកគេមានវត្តមានដើម្បីជួយដល់អ្នកទាមទារសំណងក្នុងការវាយតម្លៃលើការខាតបង់ នៃអាជីវកម្មរបស់អ្នកទាមទារប៉ុណ្ណោះ។ ថ្លៃចំណាយសមស្របពាក់ព័ន្ធការងាររបស់ក្រុមហ៊ុនគណនេយ្យទាំងនេះ អាចត្រូវបានបូកបន្ថែមចូលជាមួយនឹងការទាមទារថ្លៃខូចខាតជារួមដែលបានដាក់មកដោយអ្នកទាមទារ ហើយនឹងត្រូវបានបង់ប្រាក់ជូនដោយ GCCF ក្នុងលក្ខណៈជាផ្នែកមួយនៃសំណងថ្លៃខូចខាតដែលផ្ដល់ទៅឱ្យអ្នកទាមទារសំណងដែលបង្ហាញពីការខាតបងបណ្ដាលមកពីការកំពប់ប្រេង។

3. ក្នុងការណីសមស្របមួយចំនួន GCCF នឹងដោះស្រាយបញ្ហាជាបណ្ដឹងទាមទារជាក្រុមដែលដាក់ដោយមេធាវី ឬ ជាក្រុមហ៊ុនសេវាច្បាប់ ក្រុមហ៊ុនគណនេយ្យជាក់លាក់ណាមួយ ឬ ជាតំបន់ក្នុងមូលដ្ឋានជាក់លាក់ នៃឈូងសមុទ្រ ដោយបញ្ជូនគណនេយ្យកររបស់ GCCF ឬ បុគ្គលិកគាំទ្ររបស់ GCCF ឱ្យទៅជួបជាមួយនឹង មេធាវី ក្រុមហ៊ុនគណនេយ្យ ឬ អ្នកទាមទារសំណងក្នុងតំបន់មានមូលដ្ឋានជាក់លាក់មួយក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហានៃបណ្ដឹងទាមទារសំណងឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធផលនៅត្រឹមថ្នាក់មូលដ្ឋាន។

4. ចំពោះបណ្ដឹងទាំងអស់ក្រៅពីបណ្ដឹងចំពោះការមានរបួសដល់រាងកាយ ប្រសិនបើអ្នកទាមទារសំណងមិនយល់ព្រមនឹងសេចក្ដីសម្រេចរបស់ GCCF ទេនោះ (មិនថា វាត្រូវបានបដិសេធ ឬ អ្នកទាមទារសំណងគិតថា សំណងមិនគ្រប់នោះទេ) ឬ ប្រសិនបើ GCCF មិនបានអើពើអំពីបណ្ដឹងទាមទារក្នុងអំឡុងពេល 90 ថ្ងៃ នៃកាលដែលបណ្ដឹងត្រូវបានទៅដល់ក្រុមហ៊ុន BP ឬ GCCF ទេនោះ អ្នកទាមទារសំណងអាចបញ្ជូនបណ្ដឹងរបស់ខ្លួនទៅ National Pollution Funds Center ("NPFC") ការិយាល័យឆ្មាំឆ្នេរសមុទ្រ (Coast Guard) ដែលទទួលបន្ទុកលើការវាយតម្លៃ និងអនុម័តបណ្ដឹងទាមទារសំណងក្រោមច្បាប់បំពុលដោយសារប្រេង (OPA) ឬក៏លោកអ្នកអាចមានសិទ្ធិដាក់ពាក្យបណ្ដឹងទៅតុលាការ រួមមាននៅក្នុងនីតិវិធីបណ្ដឹងពិសេសរបស់រដ្ឋសហព័ន្ធ ដែលកំពុងរង់ចាំការជំនុំជម្រះនៅចំពោះមុខតុលាការ United States District Court សម្រាប់ the Eastern District of Louisiana ក្នុងរឿងក្ដី*Oil Spill by the Oil Rig "Deepwater Horizon" នៅឈូងសមុទ្រMexico ថ្ងៃទី20 ខែមេសា ឆ្នាំ2010(MDL No. 2179)* នីតិវិធីបណ្ដឹងពិសេសរបស់រដ្ឋសហព័ន្ធគឺជាការផ្តុំបញ្ចូលគ្នានូវពាក្យបណ្ដឹងផ្សេង ក្នុងរដ្ឋសហព័ន្ធផ្សេងៗដែលកើតចេញពីការកំពប់ប្រេង។ ព័ត៌មានទូទៅស្តីពីនីតិវិធីដាក់ពាក្យបណ្ដឹងទាមទារនៅ NPFC អាចរកបានពីប្រធាន National Pollution Funds Center, NPFC MS 7100, U.S. Coast Guard, 4200 Wilson Blvd., Suite 1000, Arlington, VA 20598-7100, (800) 280-7118, ឬពីគេហទំព័រ NPFC តាមអាសយដ្ឋាន www.uscg.mil/npfc/claims។ ព័ត៌មានពាក់ព័ន្ធនឹងបណ្ដឹងតុលាការសហព័ន្ធ អាចរកបានពីវិបសាយរបស់តុលាការតាម www.laed.uscourts.gov។

5. ដូចគ្នាទៅនឹងបណ្ដឹងទាំងអស់ រួមទាំងបណ្ដឹងអំពីការមានរបួសដល់រាងកាយផងដែរ ស្របតាមពិធីសាររបស់ GCCF ដែលគ្រប់គ្រងលើបណ្ដឹងអំពីបញ្ហាហិរញ្ញវត្ថុ អ្នកទាមទារសំណងអាចប្តឹងតបបានចំពោះការកំណត់លើបណ្ដឹងទាមទារចុងក្រោយរបស់ GCCF ប្រសិនបើរូបិយវត្ថុសរុបដែលត្រូវផ្តល់ឱ្យ (រាប់បញ្ចូលទាំងសំណងបន្ទាន់ សំណងបណ្ដោះអាសន្ន និងសំណងចុងក្រោយដែលផ្ដល់ដោយក្រុមហ៊ុន BP ឬ GCCF) មានចំនួនលើសពី 250 000 ដុល្លារ ។ បណ្ដឹងឧទ្ធរណ៍នឹងត្រូវបានពិនិត្យបន្ថែមដោយក្រុមបុគ្គលអព្យាក្រឹត្យចំនួន បី រូប (មិនត្រូវបានជ្រើសរើសដោយ GCCF) ដែលជាអ្នកកំណត់ដោយឯករាជ្យលើតម្លៃនៃការទាមទារ។ ក្រុមហ៊ុន BP នឹងមានសិទ្ធិប្តឹងតបប្រឆាំងនឹងក្រុមបុគ្គលអព្យាក្រឹត្យ បី រូប នោះ ប្រសិនបើអ្នកទាមទារសំណងទទួលបានសំណងថ្លៃខូចខាតលើសពី 500 000 ដុល្លារនោះ។

**ក្រុមហ៊ុន GCCF នឹងបន្តត្រួតពិនិត្យតាមដាន និងពិនិត្យឡើងវិញលើច្បាប់ចុងក្រោយទាំងនេះដែលគ្រប់ គ្រងលើជម្រើសនៃការសងប្រាក់ ភាពមានសិទ្ធិ និងលក្ខណាវិនិច្ឆ័យនៃការបញ្ជាក់ភស្តុតាង និងវិធីសាស្ត្រសម្រាប់ការសងប្រាក់ចុងក្រោយ។ GCCF សូមស្វាគមចំពោះមតិយោបល់ជាបន្តបន្ទាប់ពីអ្នកទាមទារសំណង និងភាគីដែលមានចំណាប់អារម្មណ៍ដទៃៗទៀតស្របពេលដែលខ្លួនកំពុងដំណើរឆ្ពោះទៅមុខជាមួយនឹង ការសងប្រាក់ចុងក្រោយ សំណងបណ្ដោះអាសន្ន និងការសងរហ័ស។**

## ឯកសារភ្ជាប់A

### ការស្វែងរកភស្តុតាងដែលទាក់ទងដល់ការកំពប់ប្រេង

GCCF នឹងពិនិត្យបណ្តឹងទាមទារ សំណងម្តងមួយករណីៗដើម្បីកំណត់ថាតើអ្នកទាមទារសំណងបានស្វែងរកឃើញឬអត់ថាការខាតបង់ផ្នែកហិរញ្ញវត្ថុត្រូវបានកើតឡើងជាលទ្ធផលនៃការកំពប់ប្រេង។ ការណែនាំខាងក្រោមត្រូវបានរៀបចំឡើង ដើម្បជួយសម្រួលដល់អ្នកទាមទារសំណងក្នុងការធ្វើបណ្តឹងទាមទារសំណងជាមូលដ្ឋាន និង ផ្តល់ ឯកសារយោងគ្រប់គ្រាន់។

| ការបញ្ជាក់អះអាង | ការពិពណ៌នា | ឧទាហរណ៍នៃភស្តុតាង |
|---|---|---|
| ការខាតបង់ដោយសារតែឥទ្ធិពលនៃការកំពប់ប្រេងលើវដ្តនៃការផ្គត់ផ្គង់អាហារសមុទ្រក្នុងតំបន់ឈូង | ការប្រើប្រាស់ និង/ឬ ការពឹងពាក់ទៅលើអាហារសមុទ្រក្នុងតំបន់ឈូងសមុទ្រត្រូវតែបង្កើតឡើង។ ការរៀបចំឯកសារដើម្បីគាំទ្រដល់ការបញ្ជាក់អះអាងនេះអាចនឹងរាប់បញ្ចូលទាំងភស្តុតាងនៃប្រភពអាហារសមុទ្រពីតំបន់ឈូងសមុទ្រហើយ/ឬ ត្រូវពឹងផ្អែកលើសកម្មភាពនេសាទជាលក្ខណៈជំនួញ។<br><br>ឧទាហរណ៍៖ ក្រុមហ៊ុនដឹកជញ្ជូនដែលមានមុខងារច្រើនដែលកុងត្រាត្រូវបានលុបចោលសម្រាប់ការដឹកជញ្ជូនអាហារសមុទ្រនៅតំបន់ឈូងសមុទ្រ។ ការរៀបចំឯកសារត្រឹមត្រូវដើម្បីគាំទ្រការអះអាងនេះអាចរួមបញ្ចូលកិច្ចព្រមព្រៀង ដើមនិងលិខិតពីអតិថិជន/អ្នកផ្គត់ផ្គង់ ដោយពន្យល់ថាកុងត្រាត្រូវបានលុបចោលជាលទ្ធផល នៃការកំពប់ប្រេង។ | • បញ្ជីអតិថិជន/អ្នកផ្គត់ផ្គង់នៅក្នុងតំបន់ឈូងសមុទ្រ<br>• ភស្តុតាងនៃការបញ្ជាទិញ/កិច្ចព្រមព្រៀង/កុងត្រាដែលត្រូវបានលុបចោលដែលជាលទ្ធផលនៃការកំពប់ប្រេង<br>• ភស្តុតាងនៃការបញ្ជាទិញ/កិច្ចព្រមព្រៀង/កុងត្រាដែលត្រូវបានកែប្រែដែលជាលទ្ធផលនៃការកំពប់ប្រេង<br>• ភស្តុតាងជាប្រវត្តិសាស្ត្រនៃការបញ្ជាទិញដែលត្រូវរៀបចំឡើងដោយមានស្ថិរភាព<br>• សំបុត្របញ្ជាក់/លិខិតរបស់ភាគីទី3<br>• វិក្កយបត្រ/បង្កាន់ដៃរបស់ភាគីទី3នៃផលិតផលអាហារសមុទ្រក្នុងតំបន់ឈូងសមុទ្រ<br>• ភស្តុតាងក្នុងតំបន់ប្រពៃណីនៃសកម្មភាពជំនួញដែលត្រូវបានប៉ះពាល់ |
| ការខាតបង់ដោយសារតែឥទ្ធិពលនៃការកំពប់ប្រេងទៅលើផ្នែកទេសចរណ៍ក្នុងតំបន់ឈូងសមុទ្រ | ទំនាក់ទំនងទៅនឹងឧស្សាហកម្មទេសចរណ៍ក្នុងតំបន់ឈូងសមុទ្រត្រូវតែបង្កើតឡើង។ ការរៀបចំឯកសារដើម្បីគាំទ្រដល់ការអះអាងនេះអាចរួមបញ្ចូលទាំងភស្តុតាងនៃទំនាក់ទំនងជំនួញនិងជំនួញ ឬ អតិថិជនដំបូងដែលផ្អែកលើអ្នកទេសចរណ៍ក្នុងតំបន់។<br><br>ឧទាហរណ៍៖អ្នកចែកចាយការ៉េមក្នុងតំបន់ជាមួយនឹងការខាតបង់នៃការលក់ចំពោះសណ្ឋាគារនិងភោជនីយដ្ឋានដែលនៅជាប់ឆ្នេរសមុទ្រ។ ការប្រមូលឯកសារត្រឹមត្រូវដើម្បីគាំទ្រការអះអាងនេះអាចរាប់បញ្ចូលទាំងបញ្ជីដែលឆ្លុះបញ្ចាំងពីការកាត់បន្ថយការទិញក្រោយពេលធ្លាក់ចុះអតិថិជនដែល ពឹងផ្អែកលើផ្នែក ទេសចរណ៍ និងលិខិតពីអ្នកទិញដោយពន្យល់ថាមានការកាត់បន្ថយក្នុងការបញ្ជាទិញជា លទ្ធផលនៃការកំពប់ប្រេង។ | • បញ្ជីអតិថិជន/អ្នកផ្គត់ផ្គង់នៅក្នុងតំបន់ឈូងសមុទ្រ<br>• ភស្តុតាងនៃការបញ្ជាទិញ/កិច្ចព្រមព្រៀង/កុងត្រាដែលត្រូវបានលុបចោលដែលជាលទ្ធផលនៃការកំពប់ប្រេង<br>• ភស្តុតាងនៃការបញ្ជាទិញ/កិច្ចព្រមព្រៀង/កុងត្រាដែលត្រូវបានកែប្រែដែលជាលទ្ធផលនៃការកំពប់ប្រេង<br>• ភស្តុតាងជាប្រវត្តិសាស្ត្រនៃការបញ្ជាទិញដែលត្រូវរៀបចំឡើងដោយមានស្ថិរភាព<br>• សំបុត្របញ្ជាក់ /លិខិតរបស់ភាគីទី3<br>• សំបុត្របញ្ជាក់ /លិខិតរបស់ភាគីទី3<br>• ភស្តុតាងក្នុងតំបន់ប្រពៃណីនៃសកម្មភាពជំនួញដែលត្រូវបានប៉ះពាល់<br>• កំណត់ត្រានៃការលក់ដែលឆ្លុះបញ្ចាំងពីភាគរយនៃការលក់របស់អ្នកទិញក្រៅរដ្ឋ/អ្នកទិញក្រៅទីប្រជុំជន។ |

| | | |
|---|---|---|
| ការខាតបង់ដោយសារតែការជំនួញដែលជាលទ្ធផលផ្ទាល់ពីការកំពប់ប្រេង | ការផ្អាកជំនួញអាចរួមបញ្ចូលទាំងការអសមត្ថភាពដោយផ្នែកឬទាំងស្រុងចំពោះសកម្មភាពជំនួញ។ ឧទាហរណ៍៖ការរកស៊ីដឹកជញ្ជូនដែលមានលក្ខណៈជាជំនួញដែលធ្លាប់ជួបប្រទះការផ្អាកការរកស៊ីដោយផ្នែកនៅពេលដែលផ្លូវទឹកដែលនាវាដឹកប្រេងជាធម្មតាឆ្លងកាត់ត្រូវបានបិទចរាចរជាបណ្តោះអាសន្នដោយសារតែការកំពប់ប្រេង។ឧទាហរណ៍៖ការរកស៊ីដឹកជញ្ជូនដែលមានលក្ខណៈជាជំនួញដែលធ្លាប់ជួបប្រទះការផ្អាកការរកស៊ីដោយផ្នែកនៅពេលដែលផ្លូវទឹកដែលនាវាដឹកប្រេងជាធម្មតាឆ្លងកាត់ត្រូវបានបិទចរាចរជាបណ្តោះអាសន្នដោយសារតែការកំពប់ប្រេង។<br>ការរៀបចំឯកសារត្រឹមត្រូវដើម្បីគាំទ្រការអះអាងនេះអាចរាប់បញ្ចូលទាំងភស្តុតាងផ្លូវនាវាពីមុនដែលឆ្លងកាត់តំបន់ដែលត្រូវបានបិទនិងទំនាក់ទំនងព្រមគ្នារវាងអ្នកទារសំណង<br>និងអតិថិជនរាយការណ៍អំពីមូលហេតុដែលបណ្តាលឱ្យមានការពន្យារពេល។ | • បញ្ជីអតិថិជន/អ្នកផ្គត់ផ្គង់នៅក្នុងតំបន់ឈូងសមុទ្រ<br>• ភស្តុតាងនៃការបញ្ជាទិញ/កិច្ចព្រមព្រៀង/កុងត្រាដែលត្រូវបានលុបចោលដែលជាលទ្ធផលនៃការកំពប់ប្រេង<br>• ភស្តុតាងនៃការបញ្ជាទិញ/កិច្ចព្រមព្រៀង/កុងត្រាដែលត្រូវបានកែប្រែដែលជាលទ្ធផលនៃការកំពប់ប្រេង<br>• ភស្តុតាងជាប្រវត្តិសាស្ត្រនៃការបញ្ជាទិញដែលត្រូវរៀបចំឡើងដោយមានស្ថិរភាព<br>• សំបុត្របញ្ជាក់ /លិខិតរបស់ភាគីទី3<br>• វិក្កយបត្រ/បង្កាន់ដៃ របស់ភាគីទី3<br>• ភស្តុតាងក្នុងតំបន់ប្រពៃណីនៃសកម្មភាពជំនួញដែលត្រូវបានប៉ះពាល់ |

ឯកសារភ្ជាប់ B

ARPC
analysis•research•planning

1220 19th Street, NW

Suite 700

Washington, D.C.  20036

ទូរស័ព្ទ: (202) 797-1111

ទូរសារលេខ៖ (202) 797-3619

**ការឆ្លើយតបចំពោះការផ្តល់យោបល់ពីប្រភពនិងការគណនាពីការខូចខាតនៅពេលអនាគត**

ការខាតបង់នៅពេលអនាគតត្រូវបានគណនា នៅពេលដែលអ្នកទាមទារសំណងចង់ដាក់ *បណ្តឹងទាមទារសំណងចុងក្រោយ*។ GCCF ផ្តល់ដល់អ្នកទាមទារសំណងនូវជម្រើសទូទាត់សំណងចុងក្រោយពីរ គឺ *ការទាមទារសំណងចុងក្រោយដែលលឿន* និង *ការទាមទារសំណងចុងក្រោយ*។ វាក៏ផ្តល់ដល់អ្នក ទាមទារសំណងផងដែរនូវសមត្ថភាពទទួល*សំណង* ពាក់កណ្តាលទី។ ជម្រើសនៃការទាមទារសំណងចុងក្រោយផ្តល់សំណងដែលជាចំនួនសរុបនៃការខាតបង់របស់អ្នកទាមទារសំណងដែលកើតឡើងក្នុងឆ្នាំ2010 បូកបន្ថែមសំណងសម្រាប់ការខាតបង់នាពេលអនាគតដែលគិតទុកមុនដោយអ្នកទាមទារសំណង។ ជម្រើស នេះតម្រូវឱ្យមានការប្រមូលឯកសារនៃការខូចខាត។ ជម្រើស នេះតម្រូវឱ្យមានការប្រមូលឯកសារនៃការខូចខាត។ ការគណនាពីការខាតបង់នៅពេលអនាគតគឺស្មើនឹងការខាតបង់នៅក្នុងឆ្នាំ2010 គុណនឹងកត្តានៃ *ការស្តារឡើងវិញនៅពេលអនាគត។*។

ការផ្តល់យោបល់មួយចំនួនត្រូវបានទទួលយកស្តីពីប្រភពនិងការគណនាពីកត្តានៃការស្តារឡើងវិញនៅពេល អនាគតនៅក្នុងជម្រើសនៃការទាមទារសំណងចុងក្រោយ។ ការផ្តល់យោបល់ផ្តោតទៅលើបញ្ហាពីរយ៉ាង។ បញ្ហាមួយគឺលំដាប់ទំហំកត្តានៃការស្តារឡើងវិញ។ តើកត្តានោះមានកម្រិតខ្ពស់គ្រប់គ្រាន់ឬនៅ - តើវាឱ្យតម្លៃទាបទៅលើការខាតបង់ដែលប្រឈមមុខនឹងអ្នកទាមទារសំណងនៅពេលអនាគតដែរឬទេ? បញ្ហាទី2 គឺថាកត្តានោះត្រូវបានប្រើប្រាស់សម្រាប់តែការខាតបង់ក្នុងឆ្នាំ2010 ជាជាងការខូចខាតក្នុងមួយឆ្នាំពេញ។ ចំពោះគោលបំណងដែលអាចសម្រេចទៅបាន ដែលឥទ្ធិពលហិរញ្ញវត្ថុនៃការកំពប់ប្រេង មិនបានចាប់ផ្តើមរហូតដល់ខែឧសភា ដោយសារតែការខាតបង់នៅក្នុងឆ្នាំ2010គឺសម្រាប់តែរយៈពេលប្រាំបីខែតែប៉ុណ្ណោះ។

*ប្រភពកត្តានៃការស្តារឡើងវិញនាពេលអនាគត*

GCCF បានធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងជំនាញការខាងក្រៅដើម្បីប៉ាន់ប្រមាណឥទ្ធិពលដែលកើតឡើងពី ការកំពប់ប្រេងទៅលើសេដ្ឋកិច្ចក្នុងតំបន់ឈូងសមុទ្រ។ វាត្រូវបានកំណត់ថាការកំពប់ប្រេងមានផលប៉ះពាល់ ពីរយ៉ាង៖ (1) ផលប៉ះពាល់លើវិស័យទេសចរណ៍ ហើយនិង (2) ផលប៉ះពាល់លើអ្នកប្រមូលផល និងផ្នែក ផ្សេងៗដែលពាក់ព័ន្ធពីការបិទផ្លូវទឹក ហើយនិងការខូចខាតចំពោះការរក្សាទុក ត្រី បង្គារ ក្តាម ខ្យង និងប្រភេទសត្វផ្សេងៗ។

ប្រភពកត្តានៃការស្តារឡើងវិញនាពេលអនាគតគឺផ្អែកទៅលើការវិភាគលើបទពិសោធន៍ស្តារសេដ្ឋកិច្ចរបស់ ជំនួញនិងបុគ្គលទាំងឡាយអនុលោមទៅតាមព្រឹត្តិការណ៍មិនអាចប៉ាន់ស្មានបាននិងព្រឹត្តិការណ៍មហន្តរាយដ៏ទៃទៀត។ ជំនាញការបានធ្វើការសិក្សាជាច្រើនពីព្រឹត្តិការណ៍ទាំងនោះពីអតីតកាលហើយបានកត់ត្រាទុកនូវអត្រាដែលត្រូវបានប៉ាន់ប្រមាណនៃការស្តារសេដ្ឋកិច្ចឡើងវិញ។ ប្រភពកត្តានៃការស្តារឡើងវិញនាពេលអនាគតគឺផ្អែកទៅលើការវិភាគលើបទពិសោធន៍ស្តារសេដ្ឋកិច្ចរបស់ ជំនួញនិងបុគ្គលទាំងឡាយអនុលោមទៅតាមព្រឹត្តិការណ៍មិនអាចប៉ាន់ស្មានបាននិងព្រឹត្តិការណ៍មហន្តរាយដ៏ទៃទៀត។

*ផលប៉ះពាល់លើទេសចរណ៍*

វាត្រូវបានរំពឹងថាការខាតបង់ផ្នែកហិរញ្ញវត្ថុដ៏ធំ ដែលបង្កឡើងដោយការកំពប់ប្រេងជាលទ្ធផលចេញពីផល ប៉ះពាល់លើទេសចរណ៍។ វាត្រូវបានរំពឹងថាការខាតបង់ផ្នែកហិរញ្ញវត្ថុដ៏ធំ ដែលបង្កឡើងដោយការកំពប់ប្រេងជាលទ្ធផលចេញពីផល ប៉ះពាល់លើទេសចរណ៍។ សេដ្ឋកិច្ចក្នុងតំបន់ឈូងសមុទ្រគឺពឹងផ្អែកយ៉ាងច្រើនលើវិស័យទេសចរណ៍និង ចំណូលដែលបានមកពីវិស័យទេសចរណ៍មានឥទ្ធិពលយ៉ាងធំធេងទៅលើវិស័យសេដ្ឋកិច្ច។វាច្បាស់ណាស់ ថាការកំពប់ប្រេងបានកាត់បន្ថយវិស័យទេសចរណ៍ក្នុង2010ដោយបានកាត់បន្ថយចំណូលរបស់បុគ្គលនិងការរកស៊ីទាំងឡាយដែលពឹងផ្អែកលើទេសចរណ៍។ ម្យ៉ាងវិញទៀត ផលប៉ះពាល់លើវិស័យទេសចរណ៍នឹង ទំនងជាបន្តទៅអនាគត។ តាមពិត ពិសោធន៍ដែលទទួលបានពីព្រឹត្តិការណ៍ទាំងឡាយដែលជះឥទ្ធិពលលើវិស័យទេសចរណ៍បានឱ្យដឹងថាការខាតបង់ទាំងនេះនឹងបន្ត(ទោះបីស្ថិតក្នុងកម្រិតថយចុះក៏ដោយ) ទៅមុខ ពីរ ឬបីឆ្នាំទៀតគិតពីរយៈពេលនៃការកំពប់ប្រេង។

មានបញ្ហាចំបងពីរគឺ៖ (1) រយៈពេលរហូតដល់វិស័យទេសចរណ៍វិលទៅរកសភាពដើមវិញទាំងស្រុង និង (2) អត្រានៃការវិលទៅរកភាពដើមវិញ។ មានភាពខុសគ្នាមួយដ៏សំខាន់រវាងបញ្ហាទាំងពីរនេះ។ បញ្ហាទីមួយពាក់ព័ន្ធដោយត្រង់ទៅលើថា តើវានឹងត្រូវចំណាយរយៈពេលប៉ុន្មានខែទៀត ដើម្បីឱ្យចំនួននៃអ្នកទេសចរណ៍ និង ប្រាក់ដុល្លារដែលគេចំណាយអាចត្រូវបានលេចឡើងដោយគ្មានលំហូរនៃប្រេងឥន្ធនៈ។ បញ្ហាទី2 មានលក្ខណៈស៊ាំញុំាជាងនេះបន្តិច។ បញ្ហាទី2 មានលក្ខណៈស៊ាំញុំាជាងនេះបន្តិច។ គេត្រូវព្រួយបារម្ភជាមួយនឹងល្បឿននៃការវិលត្រឡប់ទៅរកសភាពដើមវិញ។ ប្រសិនបើវាត្រូវការរយៈពេល 30 ខែដើម្បីវិលទៅរកសភាពដើមវិញនោះ តើភាគរយនៃការវិលត្រឡប់នោះ មានចំនួនប៉ុន្មានដែរសម្រាប់រយៈកាល 15 ខែដំបូង? ល្បឿននៃការវិលត្រឡប់ទៅរកសភាពដើមនោះ មានសារៈសំខាន់ស្មើនឹងការប៉ាន់ស្មានការខូចខាតទាំងពួងនាពេលអនាគត ប្រៀបនឹង ការស្តារទាំងស្រុងវិញ។

ល្បឿននៃការវិលត្រឡប់ទៅរកសភាពដើមនោះ មានសារៈសំខាន់ស្មើនឹងការប៉ាន់ស្មានការខូចខាតទាំងពួងនាពេលអនាគត ប្រៀបនឹង ការស្តារទាំងស្រុងវិញ។ ការស្រាវជ្រាវបានរួមបញ្ចូលទាំងការវិភាគនូវព្រឹត្តិការណ៍ធំៗ រួមមានការកំពប់ប្រេងឥន្ធនៈ ព្យុះសង្ឃរា ភេរវកម្ម បញ្ហាសុខភាព និង គ្រោះធម្មជាតិផងទាំងឡាយ។ ការត្រួតពិនិត្យឡើងវិញនេះ ក៏បានរួមបញ្ចូលការវិភាគនៃការហៀរកំពប់ប្រេងឥន្ធនៈនៅតំបន់ឈូងសមុទ្រ ដែលរៀបចំឡើងដោយ Oxford Economics ជំនួសមុខឱ្យសមាគមធ្វើដំណើរនៃសហរដ្ឋអាមេរិច ដែលបានដាក់ចំណងជើងថា «ផលប៉ះពាល់ដ៏ធំធេងនៃការហៀរកំពប់ប្រេងនាតំបន់ឈូងសមុទ្រលើវិស័យទេសចរណ៍»។

ការសន្និដ្ឋានដែលបានមកពីការពិនិត្យសារឡើងវិញ និង ការវិភាគទាំងនេះមានដូចតទៅ៖

- <u>យើងសន្មត់ថា វានឹងអាចប្រើរយៈពេល 30 ខែ សម្រាប់ទេសចរណ៍ ដើម្បីទទួលបាននូវសភាពដើម មួយពេញលេញវិញ</u> (ការវិភាគនៃOxford Economics ចុងបញ្ចប់នៃផ្នែកខាងលើ)។ ក្នុងខណៈនេះដែរ សម្រាប់ព្រឹត្តិការណ៍ចំបងមួយចំនួន ការវិលត្រឡប់ទៅរកសភាពដើមទាំងស្រុងនោះអាចត្រូវទទួល បានក្នុងរយៈកាល 12 ខែពីព្រឹត្តិការណ៍នោះ។ ការសិក្សាមួយចំនួន និង Oxford Economics បានផ្តល់ជាយោបល់ថា ការវិលទៅរកសភាពដើមពេញលេញមួយ អាចឈានទៅដល់ក្នុងរយៈពេលពី 15 ទៅ 36ខែ។
- <u>យើងសន្មត់ថាការវិលទៅរកសភាពដើមអាចលេចឡើងនៅក្នុងអត្រាសមាមាត្រ 54% នាដំណាច់ឆ្នាំ ដំបូង បន្ទាប់ពីការហៀរកំពប់ប្រេង 75% នាដំណាច់ឆ្នាំទីពីរ បន្ទាប់ពីការកំពប់ប្រេង និង ឈានទៅដល់សភាពដើមវិញពេញលេញនៅរយៈកាល 30ខែបន្ទាប់ពីការកំពប់ប្រេង។</u> អត្រានៃការស្តារនេះ ពឹងផ្អែកយ៉ាងខ្លាំងទៅលើការពិនិត្យសារឡើងវិញនៃកម្មវិធីស្រាវជ្រាវ និង ការវិភាគទាំងឡាយដែលធ្វើឡើងដោយ Oxford Economics។ វាបានទទួលឥទ្ធិពលពីការវិភាគផ្សេងៗនៃរង្វាស់បង្ហាញផ្នែកសេដ្ឋកិច្ចរបស់យើងលើវិស័យទេសចរណ៍ផងដែរ។ កត្តាទាំងនេះ រួមបញ្ចូលទាំងចំណូលផលទុននៃ សណ្ឋាគារ ចំណាយក្នុងការធ្វើដំណើរ ទស្សនកិច្ចនៃអ្នកទេសចរណ៍ ចំណូលពន្ធអាករសម្រាប់ផ្នែក ដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ ចំណូលបានពីល្បែង និង មគ្គុទេសក៏ឯទៀត។ ជាកត្តារួមមួយគេ បានផ្តល់យោបល់ថា ការវិលទៅរកសភាពដើម(ការស្តារ) អាចចាប់ផ្តើមមុនឆ្នាំ2010។
- <u>រយៈកាល 30ខែ នៃការស្តារទាំងស្រុង និង អត្រានៃការស្តារដែលបានសន្មត់ទុក នាំមកនូវកត្តានៃការស្តារមួយក្នុងចំនួន 1.0 នាពេលអនាគត។</u>

*ផលប៉ះពាល់ទៅលើអ្នកបង្កបង្កើនផល*

ផលប៉ះពាល់ទៅលើអ្នកបង្កបង្កើនផល ត្រូវបានបង្ហាញក្នុងការសិក្សាមួយដែលរៀបចំសម្រាប់ GCCF ដោយ John W. Tunnell Jr. នៃ Research Institute for Gulf of Mexico Studies, Texas A&M University, Corpus Christi, Texas ដែលមានចំណងជើងថា«ទស្សនៈមួយរបស់អ្នកជំនាញការពីពេលដែលឈូងសមុទ្រ Mexico នឹងត្រឡប់ទៅរកស្ថានភាពមុនការកំពប់ប្រេងបន្ទាប់ពីឧបទ្ទវហេតុកំពប់ប្រេង Deepwater Horizon MC 252 របស់ក្រុមហ៊ុន BP»។ បណ្ឌិត Tunnell សន្និដ្ឋានថា ក្នុងពេលដែលមានការមិនដឹង និង ការផ្សងព្រេងមួយចំនួន បង្ហាញថាឋានប្រព័ន្ធកំពុងវិលត្រឡប់ទៅរកសភាពដើមវិញយ៉ាងឆាប់រហ័ស ហើយទឹកស្ទើរតែអាចប្រើប្រាស់បានទាំងស្រុងសម្រាប់ការបង្កបង្កើនផល។ ការចង្អុលបង្ហាញទាំងនេះ ឆ្លុះបញ្ចាំងពីការវាយតម្លៃល្បឿនរូបភាពនៃ ធនធានឈូងសមុទ្ររបស់កងទាហានជើងទឹក។ ល្បឿននៃការវិលទៅរកភាពដើមផ្នែកសេដ្ឋកិច្ច នៃធនធាន របស់កងទាហានជើងទឹកអាចនឹងមិនដូចគ្នាសុទ្ធសាធនោះទេ។ ឆ្ងាយអំពីការប្រុងប្រយ័ត្នទាំងពួង GCCF បានទទួលស្គាល់ដូចគ្នានឹងការសន្មត់ទាំងឡាយដែលព្រួយបារម្ភពីការវិលទៅរកសភាពដើមនៃផ្នែកអ្នកបង្កបង្កើនផល ដូចអ្វីដែលបានទទួលស្គាល់នៅក្នុងផ្នែកទេសចរណ៍ដូច្នោះដែរ។ ករណីលើកលែងតែមួយទាក់ទងនឹងសក្តានុពលដ៏យូរអង្វែងគឺបញ្ហាពពួកខ្យង ដែលពពួកខ្យងទាំងនោះទំនងត្រូវបានសម្លាប់ក្នុងបណ្តា តំបន់មួយចំនួន ហើយក៏អាចនិយាយបានថា ក្នុងករណីខ្លះជម្រកនៃពពួកខ្យងទាំងនោះអាចត្រូវបាន បំផ្លាញ។ កត្តានៃការការស្តារឡើងវិញនាពេលអនាគត ដែលអនុវត្តទៅលើពពួក ខ្យងទាំងនោះ គឺផ្អែកទៅលើការដោះស្រាយមួយផ្សេង ដែលមានពិពណ៌នានៅកន្លែងផ្សេង។

*ការប្រើប្រាស់កត្តាស្តារឡើយវិញនៅពេលអនាគត*

បញ្ហាដែលនៅសេសសល់គឺថា តើគួរអនុវត្តការសន្និដ្ឋានទាំងនេះ ទៅនឹងកាលៈទេសៈបុគ្គលនៃអ្នកទាមទារ  សំណងនីមួយៗយ៉ាងដូចម្តេច។ ទីមួយ គេសន្និដ្ឋានថា រាល់អ្នកទាមទារសំណងនឹងមានបទពិសោធដូចទៅនឹងអត្រានៃការស្តារនៃសេដ្ឋកិច្ចឈ្នួងសមុទ្រក្នុងសភាពទូទៅ។ ក្នុងពេលដែលយើងយល់ថា អ្នកទាមទារសំណងពិតជាអាចទាមទារនូវការខាតបង់របស់ពួកគេក្នុងឆ្នាំ2010 ក្នុងអត្រាខុសៗគ្នា មិនអាចធ្វើទៅបានទេក្នុងការពន្យល់នូវភាពខុសគ្នាទាំងនេះ។ វាជាការពិបាកក្នុងការវែកញែកនូវឥទ្ធិពលខុសប្លែកគ្នាគ្រប់ផ្នែក ទាក់ទិននឹងការកំពប់ប្រេង ទៅលើអ្នកទាមទារសំណងប្រឈមមុខជាមួយនឹងការចង់បានរបស់បុគ្គលម្នាក់ៗ និង ចរិកលក្ខណៈនានា ដែលមិនពាក់ព័ន្ធនឹងការកំពប់ប្រេង។

ទី2៖ ការខូចខាតនាឆ្នាំ2010 បានត្រូវជ្រើសរើសជាមូលដ្ឋាននៃការដោះស្រាយ។ យើងដឹងថាវាមានរយៈពេលប្រាំបីខែប៉ុណ្ណោះ ប៉ុន្តែគេសន្មត់ថា វាជាអំឡុងពេលមួយដែលបង្កើតឱ្យមានការខូចខាតដ៏ធំធេងបំផុត។ បន្ថែមពីលើនេះ កត្តាស្តារឡើងវិញក្នុងពេលអនាគតត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហា ត្រឹមរយៈពេល ប្រាំបីខែប៉ុណ្ណោះ ដែលជាអំឡុងពេលដំបូងបង្អស់។ ជាការពិត ចំនួនសំណងសរុបដែលបានដោះស្រាយជូន ដល់អ្នកទាមទារសំណង ដោយប្រើរយៈពេលប្រាំបីខែជាមូលដ្ឋាន គឺដូចទៅនឹងការផ្តល់សំណងក្នុងរយៈកាលដប់ពីរខែដូច្នោះដែរ។ ប្រសិនក្នុងករណីដែលអ្នកទាមទារសំណងជាបុគ្គលម្នាក់ មិនមែនជាការពិតនោះទេ ដូច្នេះ (ដូចមានព័ត៌មាននៅកន្លែងផ្សេង) ជានិច្ចកាល សំណងពាក់កណ្តាលទីអាចធ្វើទៅបាន។ បើមិនដូច្នោះទេផ្អែកទៅលើសំណងពេញមួយឆ្នាំ អាចមានន័យថា គ្មានអ្នកទាមទារសំណងណា អាចដាក់ពាក្យបណ្តឹងទាម ទារសំណងចុងក្រោយ បានមុនដំណាច់ខែមេសា ឆ្នាំ2011 នោះទេ។

## ឯកសារភ្ជាប់ C

## ការសាកល្បងផ្នែកហិរញ្ញវត្ថុ

ការសាកល្បងផ្នែកហិរញ្ញវត្ថុ គឺដើម្បីរកឱ្យឃើញថាតើមានការខូចខាតដែលបណ្តាលមកពីការកំពប់ប្រេង

- ទីមួយ ឆ្នាំ2010 ត្រូវបានបែងចែកជាពីរផ្នែក គឺ មុនពេលប្រេងកំពប់ និង ក្រោយពេលកំពប់

- ដំណាក់កាលមុនការកំពប់ប្រេង គឺចាប់ពីខែមករា ដល់ ខែមេសា
- ដំណាក់កាលក្រោយការកំពប់ប្រេង គឺចាប់ឧសភា ដល់ ខែធ្នូ

- ទីពីរ ចាប់ពីខែមករា ដល់ ខែមេសា ការចាត់ចែងផ្នែកហិរញ្ញវត្ថុក្នុងឆ្នាំ2010 បានត្រូវប្រៀបធៀបទៅនឹងមធ្យមភាគនៃការចាត់ចែងផ្នែកហិរញ្ញវត្ថុ ចាប់ពីខែឧសភា ដល់ ខែធ្នូ នៃឆ្នាំមុនៗ(ឧទាហរណ៍ ចាប់ពីខែ ឧសភា ដល់ ខែធ្នូ ឆ្នាំ 2008/2009) ដែលជាការចាត់ចែងផ្នែកហិរញ្ញវត្ថុមុនការកំពប់ប្រេង។

- ទីបី ចាប់ពីខែឧសភា ដល់ ខែធ្នូ ចំណាត់ចែងផ្នែកហិរញ្ញវត្ថុនាដំណាច់ឆ្នាំ ក្នុងឆ្នាំ2010 ត្រូវបានប្រៀបធៀបទៅនឹងមធ្យមភាគនៃការចាត់ចែងផ្នែកហិរញ្ញវត្ថុ ចាប់ពីខែឧសភា ដល់ ខែធ្នូ នៃឆ្នាំមុនៗ(ឧទាហរណ៍ ចាប់ពីខែ ឧសភា ដល់ ខែធ្នូ ឆ្នាំ 2008/2009) ដែលជាការចាត់ចែងផ្នែកហិរញ្ញវត្ថុក្រោយការកំពប់ប្រេង។

លក្ខណៈគុណវុឌ្ឍសម្រាប់ទទួលសំណង ចំណាត់ចែងផ្នែកហិរញ្ញវត្ថុត្រូវបង្ហាញ៖

- #1: ការធ្លាក់ចុះនៃចំណូល ពីមធ្យមភាគនៃចំណូលទទួលបានចាប់ពីខែឧសភា រហូតដល់ ខែធ្នូក្នុង ឆ្នាំ 2008/2009។ ក្នុងផលប៉ះពាល់នេះ ផ្នែកជំនួញត្រូវបង្ហាញថា មានការធ្លាក់ចុះនូវចំណាត់ចែងផ្នែកហិរញ្ញវត្ថុ ក្នុងរយៈកាលក្រោយការកំពប់ប្រេងដែលជាប់ពាក់ព័ន្ធទៅនឹងឆ្នាំមុន។

- #2: ភាគរយនៃការធ្លាក់ចុះនៃប្រាក់ចំណូលក្រោយការកំពប់ប្រេងនាឆ្នាំ2010 ពីចំណុច #1 ខាងលើត្រូវធ្វើ ឱ្យលើសភាគរយដែលធ្លាក់ចុះនៃប្រាក់ចំណូលមុនការកំពប់ប្រេង ក្នុងឆ្នាំ 2010។

## ភ្ជាប់D

## តម្រូវការសម្រាប់ការចងក្រងឯកសារ

### ឯកសារដែលតម្រូវដោយស្ថាបនសម្របសម្រួលបណ្តឹងទាមទារសំណងសម្រាប់តំបន់ឆ្នេរជាប់ឈូងសមុទ្រ

លោកអ្នកត្រូវផ្តល់ឯកសារ ដែលរៀបរាប់ដូចខាងក្រោម ចំពោះប្រភេទរបួស ឬការខូចខាតនីមួយៗ ដែលលោកអ្នកប្រកាសថា លោកអ្នកបានទទួលរង ដោយសារឧបទ្ទវហេតុ Deep Water Horizon Incident កាលពីថ្ងៃទី 20 ខែមេសា ឆ្នាំ 2010 និងការហៀរប្រេងចេញដែលនាំឱ្យកើតជាឧបទ្ទវហេតុ ("ការកំពប់ប្រេង")។ លក្ខខណ្ឌតម្រូវទាំងនេះអនុវត្តចំពោះពាក្យបណ្តឹងទាមទារសំណងបណ្តោះអាសន្ន និងចំពោះពាក្យបណ្តឹងទាមទារសំណងចុងក្រោយដោយមានការពិនិត្យពេញលេញ។

លក្ខខណ្ឌតម្រូវខាងក្រោមនេះគឺជាលក្ខខណ្ឌតម្រូវអប្បបរមា **ដើម្បីដំណើរការការ** ពិនិត្យលើពាក្យបណ្តឹងទាមទារសំណងរបស់លោកអ្នក។ **ក្នុងករណីខ្លះ ស្ថាបន GCCF អាចស្នើសុំឯកសារបន្ថែមទៀតពីអ្នកទាមទារសំណង។** ការផ្តល់ឯកសារគ្រប់គ្រាន់គឺជាវិធីល្អបំផុតដើម្បីធានាថា ពាក្យបណ្តឹងទាមទារសំណងរបស់លោកអ្នកត្រូវបានដាក់ឱ្យដំណើរការពិនិត្យយ៉ាងឆាប់រហ័ស។ ប្រសិនបើលោកអ្នកមានឯកសារ ឬព័ត៌មានបន្ថែមទៀត ដែលមានសារប្រយោជន៍ក្នុងការជួយបង្ហាញទៅស្ថាបន GCCF ឱ្យដឹងថាតើការកំពប់ប្រេងបណ្តាលឱ្យលោកអ្នកខាតបង់របៀបណា ឬចំនួននៃការខាតបង់នោះ លោកអ្នកគួរតែផ្តល់ឯកសារ ឬព័ត៌មាននោះ។ **គ្រប់ឯកសារទាំងអស់ ដែលលោកអ្នកបានផ្ញើដើម្បីបង្ហាញពីការខាតបង់កន្លងមក ឬប៉ាន់ប្រមាណការខាតបង់របស់លោកអ្នកនៅអនាគត នឹងត្រូវពិនិត្យ និងពិចារណាដោយស្ថាបន GCCF។**

ពាក្យបណ្តឹងទាមទារសំណងបណ្តោះអាសន្ននឹងត្រូវបានវាយតម្លៃដោយផ្អែកតែលើឯកសារ ដែលបានដាក់មក ហើយការខ្វះឯកសារនឹងបណ្តាលឱ្យមានការបដិសេធចោលនូវពាក្យបណ្តឹងទាមទារសំណងបណ្តោះអាសន្នរបស់លោកអ្នក ឬនូវការទូទាត់សំណងតិចតួចជាងនេះ។ ប្រសិនបើពាក្យបណ្តឹងទាមទារសំណងបណ្តោះអាសន្នរបស់លោកអ្នកត្រូវបានបដិសេធចោល ឬទូទាត់សងក្នុងចំនួនតិចជាងក្នុងពាក្យបណ្តឹងទាមទារសំណង ដោយសារខ្វះឯកសារ នោះលោកអ្នកនឹងមិនអាចដាក់ពាក្យបណ្តឹងទាមទារសំណងបណ្តោះអាសន្នមួយទៀតឡើយ រហូតដល់ត្រីមាសបន្ទាប់ក្នុងប្រតិទិន។ ស្ថាបន GCCF នឹងផ្ញើសេចក្តីជូនដំណឹងពីការខ្វះខាត ដោយស្នើសុំឯកសារដែលខ្វះក្នុង ពាក្យបណ្តឹងទាមទារសំណងចុងក្រោយដោយមានការពិនិត្យពេញលេញ នៅពេលដែលចាំបាច់ ប៉ុន្តែឯកសារមិនគ្រប់គ្រាន់នឹងពន្យារការវាយតម្លៃ ហើយអាចបន្ថយចំនួនសំណងចុងក្រោយ។

ប្រសិនបើអ្នកដាក់ទម្រង់ពាក្យបណ្តឹងទាមទារ តាមប្រព័ន្ធអ៊ិនធើណែត លោកអ្នកត្រូវផ្ញើឯកសារគាំទ្រទាំងអស់ក្នុងរយៈពេលប្រាំ (5) ថ្ងៃ បន្ទាប់ពីដាក់ពាក្យតាមប្រព័ន្ធអ៊ិនធើណែតរួច។ ប្រសិនបើលោកអ្នកផ្ញើទម្រង់ពាក្យបណ្តឹងទាមទារ តាមសំបុត្រ អ៊ីមែល សេវាបញ្ជូនរហ័ស ទូរសារ ឬដោយផ្ទាល់ អ្នកត្រូវដាក់ឯកសារគាំទ្រទាំងអស់ អមជាមួយនឹងទម្រង់ពាក្យបណ្តឹងទាមទាររបស់លោកអ្នក។ ពាក្យបណ្តឹងទាមទារសំណង និងឯកសារគាំទ្រដែលដាក់មកដោយផ្ទាល់ មិនរក្សាទុកនៅការិយាល័យទទួលពាក្យបណ្តឹងទាមទារសំណងរបស់ស្ថាបន GCCF។ ឯកសារទាំងនេះនឹងបញ្ជូនទៅមណ្ឌលពិនិត្យនៃស្ថប័ន GCCF ក្នុងទីក្រុង Dublin រដ្ឋ Ohio ឬស្កេន និងបញ្ជូនទៅកាន់មណ្ឌលពិនិត្យនេះ តាមរយៈប្រព័ន្ធអ៊ិនធើណែត។

នៅពេលដាក់ឯកសារ សូមលោកអ្នកប្រាកដថា លោកអ្នកបានបញ្ចូលព័ត៌មាន ដែលឱ្យយើងកំណត់អត្តសញ្ញាណរបស់លោកអ្នក ដូចជាលេខកំណត់អ្នកទាមទារសំណង លេខសន្តិសុខសង្គម ឬលេខអត្តសញ្ញាណអ្នកបង់ពន្ធដទៃទៀត ប្រសិនបើមាន។

### I. ឯកសារដែលត្រូវការចំពោះពាក្យបណ្តឹងទាមទារលើការបាត់បង់ប្រាក់ចំណូលរបស់បុគ្គល

ជនណាក៏ដោយដែលអះអាងថាបាត់បង់ប្រាក់ចំណូលក្នុងឋានៈជានិយោជិត ឬអ្នកស៊ីប្រាក់ឈ្នួល ត្រូវផ្ញើឯកសារដែលរៀបរាប់ខាងក្រោម។ ប្រសិនបើលោកអ្នកមានការងារផ្ទាល់ខ្លួនឯង ជាម្ចាស់លើទ្រព្យដែលដាក់ជួល ឬប្រកបអាជីវកម្មជាឯកត្តនាម ហើយលោកអ្នកបង់ការចំណាយលើប្រតិបត្តិការ និងរាយការណ៍ប្រាក់ចំណូលអាជីវកម្ម តាមឯកសារក្នុងឧបសម្ព័ន្ធ C ឬទម្រង់ពន្ធអាជីវកម្មដទៃទៀត នោះចូរអ្នកប្រើបញ្ជីឯកសារសម្រាប់ពាក្យបណ្តឹងទាមទារលើការខាតបង់ប្រាក់ចំណេញអាជីវកម្ម ក្នុងផ្នែកទី II មិនមែនក្នុងបញ្ជីនេះទេ។

1. **ឯកសារដែលបញ្ជាក់ពីប្រវត្តិប្រាក់ចំណូលរបស់អ្នកពីថ្ងៃទី 1 មករា 2008 រហូតមកដល់បច្ចុប្បន្ន**

(a) សូមផ្តល់លិខិតប្រកាសពន្ធចំណូលសហព័ន្ធសម្រាប់ឆ្នាំ (income tax returns) 2008 និងឆ្នាំក្រោយៗមកទាំងអស់ រហូតដល់លិខិតប្រកាសពន្ធដែលលោកអ្នកបានដាក់ប្រកាស នាពេលថ្មីៗនេះ។ សូមរាប់បញ្ចូលនូវទម្រង់ W-2 ទម្រង់ 1099 និងឯកសារភ្ជាប់ ឬកាលវិភាគនៃលិខិតប្រកាសពន្ធនីមួយៗ។ ប្រសិនបើលោកអ្នកពុំមានលិខិតប្រកាសពន្ធចំណូលសហព័ន្ធ ចូរផ្តល់សេចក្តីថ្លែងការណ៍ដែលបានពន្យល់ពីមូលហេតុ។

(b) ចំពោះឆ្នាំមុនៗណា ដែលលោកអ្នកមិនអាចផ្តល់លិខិតប្រកាសពន្ធសហព័ន្ធ និងចំពោះឆ្នាំបច្ចុប្បន្នរហូតដល់ថ្ងៃដែលលោកអ្នកអះអាងថាបានខាតបង់ លោកអ្នកត្រូវបញ្ជាក់ពីប្រវត្តិប្រាក់ចំណូលសម្រាប់រយៈពេលទាំងមូល យ៉ាងហោចណាស់តាមរយៈប្រភពមួយក្នុងចំណោមប្រភព ដូចខាងក្រោម:

(i) លិខិតប្រកាសពន្ធរដ្ឋ ដែលរាប់បញ្ចូលទាំងទម្រង់ W-2 ទាំងអស់ ទម្រង់ 1099 និងឯកសារភ្ជាប់ ឬកាលវិភាគនៃនៃលិខិតប្រកាសពន្ធនីមួយៗ។

(ii) ចុងមូលប្បទានប័ត្រប្រាក់ឈ្នួល ឬបញ្ជីប្រាក់ខែដទៃទៀតពីកន្លែងផ្តល់ការងារទាំងអស់ ដែលបង្ហាញពីប្រាក់ចំណូលចាប់ពីថ្ងៃទី 1/1/08 រហូតដល់ពេលបច្ចុប្បន្ន។

(iii) លិខិត ឬបញ្ជីដទៃទៀតពីនិយោជក ដែលរៀបរាប់ថាតើពេលណាដែលលោកអ្នកកំពង់ធ្វើការ និងអត្រាប្រាក់ឈ្នួល និងប្រាក់ចំណូលសរុបរបស់លោកអ្នក។

**2. ឯកសារដែលបញ្ជាក់ពីផលប៉ះពាល់នៃការកំពប់ប្រេងលើប្រាក់ចំណូលរបស់លោកអ្នក**

(a) លោកអ្នកត្រូវបង្ហាញថាតើ ការកំពប់ប្រេងបានប៉ះពាល់យ៉ាងណាដល់សមត្ថភាពរបស់លោកអ្នកក្នុងការរកប្រាក់ដែលលោកអ្នកបានរំពឹងថានឹងរកបាន ដូចជាលិខិតពីតំណាងពេញសិទ្ធិរបស់និយោជករបស់លោកអ្នក ដែលរៀបរាប់ពីការបញ្ឈប់ពីការងារ ការបន្ថយម៉ោងធ្វើការ និង/ឬបន្ថយអត្រាប្រាក់ឈ្នួល ដែលបណ្តាលពីការកំពប់ប្រេង។ ប្រសិនបើលោកអ្នកមិនបានធ្វើការ ហើយគ្មានចំណូលក្នុងមួយរយៈពេល បន្ទាប់ពីការកំពប់ប្រេង ឯកសាររបស់អ្នកត្រូវតែបញ្ជាក់ថា នៅពេលណាដែលរយៈពេលគ្មានប្រាក់ចំណូលបានចាប់ផ្តើម ហើយប្រសិនបើរយៈពេលនោះបានចប់ហើយ នៅពេលណា។

(b) ប្រសិនបើលោកអ្នកបានទទួលប្រាក់ចំណូលជំនួសវិញ ដូចជាសំណងពីគោលនយោបាយធានារ៉ាប់រងការពារប្រាក់ចំណូល ឬពីផែនការផ្តាច់ការងាររបស់ក្រុមហ៊ុន លោកអ្នកត្រូវផ្ញើឯកសារដែលបញ្ជាក់ពីចំនួនទឹកប្រាក់ ហើយពីពេលណាដែលលោកអ្នកបានទទួលប្រាក់នោះ។

(c) ប្រសិនបើលោកអ្នកអត់ការងារធ្វើក្នុងមួយរយៈ បន្ទាប់ពីការកំពប់ប្រេង លោកអ្នកត្រូវបញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែងរបស់លោកអ្នក ក្នុងការរកការងារធ្វើ ឬពីមូលហេតុដែលលោកអ្នកមិនបានខិតខំរកការងារធ្វើ។ លោកអ្នកអាចបង្ហាញពីកិច្ចខិតខំប្រឹងប្រែងរកការងារធ្វើ តាមរយៈការផ្ញើឯកសារដែលលោកអ្នកទទួលបានអត្ថប្រយោជន៍គ្មានការងារធ្វើ ឬតាមរយៈការដាក់ច្បាប់ចម្លងពាក្យសុំការងារធ្វើ លិខិតបដិសេធ ឬលិខិតជូនដំណឹង ដែលចង្អុលបង្ហាញថាអ្នកគ្មានគេជួលឱ្យធ្វើការ ឬតាមរយៈការផ្តល់បញ្ជីថ្ងៃខែនៃកិច្ចខិតខំប្រឹងប្រែងរកការងារធ្វើ។ ប្រសិនបើលោកអ្នកផ្ញើបញ្ជីនោះ សូមបញ្ចូលនិយោជកដែលបានពាក់ព័ន្ធ ជនដែលបានទាក់ទង និងលទ្ធផលនៃការខិតខំប្រឹងប្រែង។

**3. ចំពោះពាក្យបណ្តឹងទាមទារសំណងចុងក្រោយដោយមានការពិនិត្យពេញលេញ — ឯកសារគាំទ្រដល់ការខូចខាតនាពេលអនាគត**

អ្នកដាក់ពាក្យបណ្តឹងទាមទារសំណង ដែលបានដាក់ទម្រង់ពាក្យបណ្តឹងទាមទារ សំណងចុងក្រោយ ដោយការពិនិត្យពេញលេញ អាចដាក់ឯកសារដែលគាំទ្របញ្ជាក់ពីចំនួន ដែលអះអាងថា នឹងជាចំនួនប្រាក់ខូចខាតនាថ្ងៃអនាគត ដោយសារការកំពប់ប្រេង ដែលរាប់បញ្ចូលទាំងឯកសារដែលបង្ហាញពីវិធីគណនាការខូចខាតនៅថ្ងៃអនាគតនោះ រយៈពេលដែលទាមទារសំណងខូចខាតពេលអនាគត និងរបាយការណ៍របស់អ្នកជំនាញ ឬការវិភាគដទៃទៀតដែលជាមូលដ្ឋានសម្រាប់ការគណនា។

**II. ឯកសារដែលទាមទារឱ្យមានសម្រាប់ពាក្យបណ្តឹងទាមទារលើការបាត់បង់ប្រាក់ចំណេញរបស់អាជីវកម្ម**

អាជីវកម្មណាក៏ដោយ ដែលអះអាងថា ខាតបង់ប្រាក់ចំណេញ ដែលបង្កឡើងដោយការកំពប់ប្រេងនោះ ត្រូវដាក់ឯកសារដែលរៀបរាប់ដូចខាងក្រោម។ ប្រសិនបើលោកអ្នកជាមានការងារផ្ទាល់ខ្លួនឯង ជាម្ចាស់លើទ្រព្យដែលដាក់ជួល ឬប្រកបអាជីវកម្មជាឯកត្តនាម ហើយលោកអ្នកបង់ការចំណាយលើប្រតិបត្តិការ និងរាយការណ៍ប្រាក់ចំណូលអាជីវកម្ម តាមឯកសារក្នុងឧបសម្ព័ន្ធ C ឬទម្រង់ពន្ធអាជីវកម្មដទៃទៀត នោះសូមលោកអ្នកប្រើបញ្ជីឯកសារនេះ មិនមែនបញ្ជីក្នុងផ្នែកទី I ឡើយ។

**1. ឯកសារដែលបញ្ជាក់ពីផលទុន និងប្រាក់ចំណូលពីថ្ងៃទី 1 មករា 2008 រហូតដល់បច្ចុប្បន្ន**

(a) សូមផ្តល់លិខិតប្រកាសពន្ធចំណូលសហព័ន្ធសម្រាប់ឆ្នាំ (income tax returns) 2008 និងឆ្នាំក្រោយៗមកទាំងអស់ រហូតដល់លិខិតប្រកាសពន្ធដែលលោកអ្នកបានដាក់ប្រកាស នាពេលថ្មីៗនេះ។ សូមរាប់បញ្ចូលនូវទម្រង់ W-2 ទម្រង់ 1099 និងឯកសារភ្ជាប់ ឬកាលវិភាគនៃលិខិតប្រកាសពន្ធនីមួយៗ។ ប្រសិនបើលោកអ្នកពុំមានលិខិតប្រកាសពន្ធចំណូលសហព័ន្ធណាមួយសម្រាប់ឆ្នាំមុនៗ សូមផ្តល់សេចក្តីថ្លែងការណ៍ណាមួយដែលពន្យល់ពីមូលហេតុ។

(b) ចំពោះឆ្នាំមុនណាមួយ ដែលអ្នកមិនអាចផ្តល់លិខិតប្រកាសពន្ធសហព័ន្ធបាន ហើយចំពោះឆ្នាំបច្ចុប្បន្នរហូតដល់ថ្ងៃដែលលោកអ្នកកំពុងទាមទារការខាតបង់ លោកអ្នកត្រូវតែបញ្ជាក់ពីប្រវត្តិផលទុន និងប្រាក់ចំណូលរបស់លោកអ្នកសម្រាប់រយៈពេលទាំងមូល យ៉ាងហោចណាស់តាមរយៈ ប្រភពមួយក្នុងចំណោមប្រភព ដូចខាងក្រោម:

(i) របាយការណ៍ខាតបង់ និងរបាយការណ៍ប្រាក់ចំណេញប្រចាំខែ និងប្រចាំឆ្នាំ។

(ii) លិខិតប្រកាសពន្ធប្រើប្រាស់ និងលក់ប្រចាំខែ។

(iii) ចំពោះអាជីវកម្មប្រមូលផលនេសាទ របាយការណ៍ ដែលទទួលបានពីទីភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធ ស្តីពីការសំចតរបស់អ្នកប្តឹងទាមទារសំណង ចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2008 មក។

(iv) ចំពោះអាជីវកម្មថ្មី របាយការណ៍ហិរញ្ញវត្ថុ និងផែនការពាណិជ្ជកម្មទាំងអស់ដែលមាន។

(c) បន្ថែមពីលើលិខិតប្រកាសពន្ធសហព័ន្ធ អ្នកប្តឹងទាមទារសំណងជាលក្ខណៈអាជីវកម្ម ដែលស្នើសុំការទូទាត់សំណងច្រើនជាង $200,000 ត្រូវដាក់របាយការណ៍ខាតបង់ និងចំណេញប្រចាំខែ និងប្រចាំឆ្នាំ ចាប់ពីឆ្នាំ 2008 រហូតមកដល់បច្ចុប្បន្ន។

**2. ឯកសារដែលបញ្ជាក់ពីផលប៉ះពាល់នៃការកំពប់ប្រេងមកលើអាជីវកម្ម**

លោកអ្នកត្រូវបង្ហាញថាតើការកំពប់ប្រេងបានប៉ះពាល់ដល់ផលទុន និងប្រាក់ចំណូលរបស់អាជីវកម្មយ៉ាងដូចម្តេច ដូចជាជាមួយនឹងលិខិតទទួលបានពីតំណាងពេញសិទ្ធិ អតិថិជន និង/ឬអ្នកលក់ដែលរៀបរាប់ពីផលប៉ះពាល់ ឬជាមួយនឹងបញ្ជីអាជីវកម្មដទៃទៀត ដូចជាបញ្ជីអតិថិជន និងវិក្កយប័ត្រ។ ចំពោះពាក្យបណ្តឹងទាមទារសំណង ដែលផ្អែកទៅលើការលុបចោលផ្នែកអាជីវកម្ម ដោយសារការកំពប់ប្រេង ដូចជាដោយសារការលុបចោលកិច្ចសន្យាជួល កិច្ចសន្យា ឬការកក់ទុកក្នុងដំណើរទេសចរណ៍ អ្នកទាមទារសំណងត្រូវផ្ញើច្បាប់ចម្លងឯកសារដែលបង្ហាញពីការលុបចោល និងឯកសារស្តីពីការប្រគល់ប្រាក់កក់វិញ ដែលបណ្តាលមកពីការលុបចោលនោះ។ អ្នកទាមទារសំណង ដែលអះអាងថាគ្មានផលទុន ឬប្រាក់ចំណូលក្នុងរយៈពេល បន្ទាប់ពីការធ្លាយចេញ ឬក៏អាជីវកម្មបរាជ័យទាំងស្រុងដោយសារការកំពប់ប្រេងនោះ ត្រូវផ្ញើឯកសារ ដូចជារបាយការណ៍ពីការខាតបង់ និងប្រាក់ចំណេញ ឬបញ្ជីហិរញ្ញវត្ថុដទៃទៀត ដែលបង្ហាញថា លោកអ្នកទាមទារសំណងបានបិទទ្វារ និង/ឬគ្មានផលទុន។

3. **ឯកសារដែលបញ្ជាក់ពីកម្មសិទ្ធិ ឬសិទ្ធិប្រកបរបរ**

អ្នកទាមទារសំណងអាជីវកម្មត្រូវតែបញ្ជាក់ថា តំណាងដែលជាអ្នកដែលចុះហត្ថលេខាលើទម្រង់ពាក្យបណ្ដឹងទាមទារសំណង មានសិទ្ធិចុះហត្ថលេខាត្រូវបាន តាងនាមឱ្យអ្នកទាមទារសំណងជាអាជីវកម្ម។ ឧទាហរណ៍នៃឯកសារ ដែលបញ្ជាក់ពីសិទ្ធិនោះ រួមមានកិច្ចព្រមព្រៀងប្រតិបត្តិការ បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ឬសេចក្ដីសម្រេចក្រុមប្រឹក្សាភិបាល កិច្ចព្រមព្រៀងម្ចាស់ភាគហ៊ុន កិច្ចព្រមព្រៀងភាពជាដៃគូ ឬលិខិតបញ្ជាក់តំណែងផ្លូវការ។ ប្រសិនបើពាក្យបណ្ដឹងទាមទារការខាតបង់ប្រាក់ចំណូលពីការជួល អ្នកទាមទារសំណងត្រូវផ្ញើច្បាប់ចម្លងនៃកម្មសិទ្ធិលើទ្រព្យសម្បត្តិដែលដាក់ជួលនោះ ដោយអ្នកទាមទារសំណងដែលជាម្ចាស់កម្មសិទ្ធិ។ ប្រសិនបើលោកអ្នកទាមទារសំណងជាក្រុមហ៊ុនអាជីវកម្មដែលមានលោកអ្នកកាន់តំណែងខ្ពស់ (ឬបុគ្គលដែលមានសិទ្ធិអំណាចស្រដៀងគ្នា) អ្នកទាមទារសំណងត្រូវតែផ្ញើបញ្ជីឈ្មោះ និងមុខតំណែងរបស់អ្នកកាន់តំណែងនីមួយៗ។

4. **ឯកសារដែលគាំទ្រថ្លៃចំណាយដែលកើនឡើង**

ប្រសិនបើអ្នកទាមទារសំណងកំពុងទាមទារថា ខ្លួនបានទទួលរងការខាតបង់ ដោយសារតែការកើនឡើងនូវថ្លៃចំណាយខាងប្រតិបត្តិការ ឬមានការចំណាយបន្ថែមទៀត ដោយសារការកំពប់ប្រេងនោះ អ្នកប្ដឹងទាមទារសំណងត្រូវផ្ញើច្បាប់ចម្លងឯកសារ ដែលគាំទ្រដល់ការកើនឡើងនូវការចំណាយនោះ។

5. **អាជ្ញាប័ណ្ណនេសាទ**

ប្រសិនបើអ្នកទាមទារសំណងអះអាងពីការខាតបង់ក្នុងការនេសាទពាណិជ្ជកម្ម ឬប្រតិបត្តិការប្រមូលផលនេសាទ នោះអ្នកទាមទារសំណង ក៏ត្រូវផ្ញើ ច្បាប់ចម្លងអាជ្ញាប័ណ្ណនេសាទដែលមានសុពលភាព ដែលចេញដោយអង្គភាពសហព័ន្ធ ឬរដ្ឋណាមួយ ដែលអ្នកប្ដឹងទាមទារសំណងបានកាន់កាប់ពីឆ្នាំ 2008 មកដល់បច្ចុប្បន្ន។

6. **ឯកសារដែលបញ្ជាក់ថាតើទ្រព្យសម្បត្តិដាក់ជួលទទួលរងការខូចខាតដោយរបៀបណា**

បណ្ដឹងទាមទារសំណងចំពោះការបាត់បង់ប្រាក់ចំណូលពីការដាក់ជួលទ្រព្យសម្បត្តិ ដោយម្ចាស់ទ្រព្យសម្បត្តិ ត្រូវមានឯកសារថាតើ ទ្រព្យសម្បត្តិដាក់ជួលនោះ ស្ថិតក្រោមការចាត់ចែងដោយម្ចាស់ទ្រព្យសម្បត្តិ ឬភាគីទី 3 ដូចជាកិច្ចព្រមព្រៀងគ្រប់គ្រង ឬវិក្កយប័ត្រពីក្រុមហ៊ុនគ្រប់គ្រងទ្រព្យសម្បត្តិ។

7. **ការធានារ៉ាប់រងលើការបាត់បង់ប្រាក់ចំណូល**

អ្នកទាមទារសំណងត្រូវមានឯកសារស្ដីពីចំនួនទឹកប្រាក់ដែលបានទទួល ឬស្មានទុកថាបានទទួលពីគោលការណ៍ ឬកម្មវិធីធានារ៉ាប់រង ចំពោះការបាត់បង់ប្រាក់ចំណូល ឬបង្អាក់រាំងស្ទះក្នុងប្រតិបត្តិការអាជីវកម្មដោយសារការកំពប់ប្រេង ក៏ដូចជាពីថ្ងៃដែលអ្នកប្ដឹងទាមទារសំណងទទួលបានប្រាក់នោះ និងថ្ងៃដែលប្រាក់នោះគ្រោងនឹងឈប់ផ្ដល់ឱ្យ។

8. **ការបន្ធូបន្ថយ**

អ្នកទាមទារសំណងត្រូវដាក់ឯកសារស្ដីពីកិច្ចខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយ ឬសម្រាលការខាតបង់ ក្នុងអំឡុងរយៈពេលមួយ ចាប់តាំងពីពេលមានការកំពប់ប្រេង។

9. **ចំពោះពាក្យបណ្ដឹងទាមទារសំណងចុងក្រោយដោយការពិនិត្យពេញលេញ— ឯកសារគាំទ្រការខូចខាតនាពេលអនាគត (ប្រសិនបើមាន)**

អ្នកដាក់ពាក្យបណ្ដឹងទាមទារសំណង ដែលបានដាក់ទម្រង់ពាក្យបណ្ដឹង ទាមទារសំណងចុងក្រោយ ដោយការពិនិត្យពេញលេញ អាចដាក់ឯកសារដែលគាំទ្របញ្ជាក់ពីចំនួន ដែលអះអាងថា នឹងជាចំនួនប្រាក់ខូចខាតនាថ្ងៃអនាគត ដោយសារការកំពប់ប្រេង ដែលរាប់បញ្ចូល ទាំងឯកសារដែលបង្ហាញពីវិធីគណនាការខូចខាតនៅថ្ងៃអនាគតនោះ រយៈពេលដែលទាមទារសំណងខូចខាតអនាគត និងរបាយការណ៍របស់អ្នកជំនាញ ឬការវិភាគដទៃទៀតដែលជាមូលដ្ឋានសម្រាប់ការគណនា។

### III. ឯកសារដែលត្រូវការចំពោះពាក្យបណ្ដឹងទាមទារថ្លៃចំណាយលើការជំរះចេញ និងការសម្អាត

បុគ្គលណាក៏ដោយ ដែលទាមទារថ្លៃចំណាយលើការជំរះចេញ និងការសម្អាត ដោយសារការកំពប់ប្រេង ត្រូវផ្ញើឯកសារដែលរៀបរាប់ដូចខាងក្រោម។

1. **ឯកសារដែលរៀបរាប់ពីសកម្មភាពជំរះចេញ និងសម្អាត**

2. **ឯកសារដែលបញ្ជាក់ពីពេលវេលា និងកន្លែងដែលធ្វើសកម្មភាពជំរះចេញ និងសម្អាត**

3. **អ្នកសម្របសម្រួលសហព័ន្ធរដ្ឋប្រចាំកន្លែងកើតហេតុ ឬផែនការណ៍រដ្ឋសម្រាប់ការអនុវត្តជាយថាហេតុ**

អ្នកទាមទារសំណងត្រូវបញ្ជាក់ថា សកម្មភាពជំរះចេញ និងសម្អាតត្រូវបានទទួលនូវ ការឯកភាពពីអ្នកសម្របសម្រួលសហព័ន្ធរដ្ឋប្រចាំកន្លែងកើតហេតុ (Federal On-Scene Coordinator) ឬត្រូវគោរពតាមផែនការណ៍រដ្ឋសម្រាប់ការអនុវត្តជាយថាហេតុ (National Contingency Plan)។

4. **ឯកសារបញ្ជាក់ពីមូលហេតុដែលធ្វើសកម្មភាពជំរះចេញ និងសម្អាត**

អ្នកទាមទារសំណងត្រូវបង្ហាញថា សកម្មភាពត្រូវបានធ្វើឡើងដោយសារការកំពប់ប្រេង ដូចជា តាមរយៈការរាប់បញ្ចូលនូវផែនទី ឬរូបភាពនៃតំបន់ដែលមានសារធាតុពុល។

**5. ឯកសារដែលបញ្ជាក់ពីថ្លៃចំណាយ និងការបង់ប្រាក់**

អ្នកទាមទារសំណងត្រូវបង្ហាញពីថ្លៃចំណាយលើសកម្មភាព និងប្រាក់ដែលពិតជាបានបង់ចំណាយ ដូចជា តាមរយៈការផ្តល់ច្បាប់ចម្លងបង្កាន់ដៃ វិក្កយប័ត្រ ឬបញ្ជីស្រដៀងគ្នា ដែលគាំទ្រលើថ្លៃចំណាយក្នុងការអនុវត្តកម្មភាព និងរបាយការណ៍ធនាគារ មូលប្បទានប័ត្រដែលលុបចោល របាយការណ៍ពីកាតឥណទាន ឬឯកសារដទៃទៀតដែលបញ្ជាក់ពីការបង់លើថ្លៃចំណាយ។

**6. ថ្លៃចំណាយដែលសមហេតុផល**

អ្នកទាមទារសំណងត្រូវពន្យល់ថាតើចំនួនដែលទាមទារឱ្យសងលើថ្លៃចំណាយត្រូវបានកំណត់ដោយរបៀបណា តាមរយៈការផ្តល់ការប្រៀបធៀបថ្លៃចំណាយ ការដេញថ្លៃ ឬការកំណត់តម្លៃជាជម្រើសផ្សេង ឬឯកសារដទៃទៀត ដែលបង្ហាញថា ថ្លៃចំណាយជាថ្លៃចំណាយដែលសមហេតុផល។

**7. ប្រាក់បានមកពីការធានារ៉ាប់រង ឬប្រភពដទៃទៀត**

អ្នកទាមទារសំណងត្រូវផ្តល់ឯកសារពីប្រាក់ដែលបានទទួលពីក្រុមហ៊ុនធានារ៉ាប់រងឯកជន ឬអង្គភាពដទៃទៀត ដើម្បីធ្វើសកម្មភាពជំរះ និងសម្អាត ទាក់ទងនឹងកម្មវត្ថុណាមួយដែលជាមូលដ្ឋាននៃការទាមទារសំណង។

**8. ចំពោះពាក្យបណ្តឹងទាមទារសំណងចុងក្រោយដោយការពិនិត្យពេញលេញ— ឯកសារគាំទ្រការខូចខាតនាពេលអនាគត (ប្រសិនបើមាន)**

អ្នកដាក់ពាក្យបណ្តឹងទាមទារសំណង ដែលបានដាក់ទម្រង់ពាក្យបណ្តឹង ទាមទារសំណងចុងក្រោយ ដោយការពិនិត្យពេញលេញ អាចដាក់ឯកសារដែលគាំទ្របញ្ជាក់ពីចំនួន ដែលអះអាងថា នឹងជាចំនួនប្រាក់ខូចខាតនាថ្ងៃអនាគត ដោយសារការកំពប់ប្រេង ដែលរាប់បញ្ចូល ទាំងឯកសារដែលបង្ហាញពីវិធីគណនាការខូចខាតនៅថ្ងៃអនាគតនោះ រយៈពេលដែលទាមទារសំណងខូចខាតអនាគត និងរបាយការណ៍របស់អ្នកជំនាញ ឬការវិភាគដទៃទៀតដែលជាមូលដ្ឋានសម្រាប់ការគណនា។

**IV. ឯកសារដែលត្រូវការចំពោះការទាមទារលើការខូចខាតអចលនទ្រព្យ និងទ្រព្យសម្បត្តិបុគ្គល**

បុគ្គលណាក៏ដោយ ដែលទាមទារសំណងលើការខូចខាតលើអចលនទ្រព្យ ឬទ្រព្យសម្បត្តិបុគ្គល ដែលបង្កឡើងដោយការកំពប់ប្រេង ត្រូវដាក់ឯកសារ ដែលរៀបរាប់ដូចខាងក្រោម។

**1. ភស្តុតាងពីផលប្រយោជន៍កម្មសិទ្ធិ**

អ្នកទាមទារសំណងត្រូវផ្តល់ឯកសារពីកម្មសិទ្ធិ ឬផលប្រយោជន៍កាន់កាប់តាមកិច្ចសន្យាជួលលើទ្រព្យសម្បត្តិដែលអះអាងថាបានទទួលរងការខូចខាត ដូចជា តាមរយៈការផ្តល់ច្បាប់ចម្លងនៃកម្មសិទ្ធិ ប័ណ្ណកម្មសិទ្ធិ ឬកិច្ចសន្យាជួលទ្រព្យសម្បត្តិ ដែលដាក់ឈ្មោះអ្នកទាមទារសំណង។ ប្រសិនបើពាក្យបណ្តឹងទាមទារសំណងទៅលើការខូចខាតនាវា ឯកសារដែលផ្ញើមកត្រូវបញ្ជាក់ពីលេខអត្តសញ្ញាណនាវា ឬនាវា។

**2. ភស្តុតាងពីការខូចខាត**

អ្នកទាមទារសំណងត្រូវបញ្ជាក់ថា ទ្រព្យសម្បត្តិបានទទួលរងការខូចខាតរូបវន្ត ឬបំផ្លាញដោយការកំពប់ប្រេង ដូចជា តាមរយៈការផ្តតល់ច្បាប់ចម្លងនៃវិក្កយប័ត្រជួសជុល ការទាមទារសំណងពីធានារ៉ាប់រង ឬរូបថត។

**3. ឯកសារដែលបញ្ជាក់ពីការបាត់បង់តម្លៃ**

ពាក្យបណ្តឹងទាមទារសំណងលើទ្រព្យសម្បត្តិ ដែលផ្អែកលើការបាត់បង់តម្លៃនៃទ្រព្យសម្បត្តិដែលខូចខាតរូបវន្ត ត្រូវបញ្ជាក់ពីការបាត់បង់ដែលមាននោះ ដូចជាតាមរយៈការផ្តល់ច្បាប់ចម្លងនៃកិច្ចសន្យាទិញ ឬលក់ទ្រព្យសម្បត្តិមុនពេលមានការកំពប់ប្រេង និងឯកសារដោះស្រាយ ឬបិទបញ្ចប់ដែលទាក់ទងនឹងការលក់ ឬការចាត់ចែងដទៃផ្សេងទៀតលើទ្រព្យសម្បត្តិ បន្ទាប់ពីការកំពប់ប្រេង។

**4. ឯកសារថ្លៃជួសជុល ឬរកជំនួស**

ពាក្យបណ្តឹងទាមទារសំណងលើការខូចខាតទ្រព្យសម្បត្តិ ដែលផ្អែកលើថ្លៃចំណាយជួសជុល ឬជំនួសទ្រព្យសម្បត្តិដែលខូចខាត ត្រូវបញ្ជាក់ពីចំនួនថ្លៃចំណាយទាំងនោះ ដូចជាតាមរយៈការផ្តល់ច្បាប់ចម្លងវិក្កយប័ត្រ ឬឯកសារប៉ាន់ប្រមាណថ្លៃជួសជុល ឬជំនួស។

**5. ប្រាក់បានមកពីការធានារ៉ាប់រង**

អ្នកទាមទារសំណងត្រូវលើកឡើង និងផ្តល់ឯកសារពីចំនួនប្រាក់ពីគោលការណ៍ ឬកម្មវិធីធានារ៉ាប់រងចំពោះទ្រព្យសម្បត្តិ ដែលទទួលរងការខូចខាតឬបំផ្លាញដោយការកំពប់ប្រេង ក៏ដូចជាថ្ងៃដែលអ្នកទាមទារសំណងបានទទួលប្រាក់នោះ។

**6. ការខូចខាតទ្រព្យសម្បត្តិ ក្នុងអំឡុងការផ្តល់ឱកាសដល់នាវាកៀប្រេង (Vessels of Opportunity)**

អ្នកទាមទារសំណងត្រូវតែបង្ហាញថាតើ ទ្រព្យសម្បត្តិបានខូចខាត ក្នុងអំឡុងពេលនៃកម្មវិធីផ្តល់ឱកាសដល់នាវាកៀប្រេង។

**7. ចំពោះពាក្យបណ្តឹងទាមទារសំណងចុងក្រោយដោយការពិនិត្យពេញលេញ— ឯកសារគាំទ្រការខូចខាតនាពេលអនាគត (ប្រសិនបើមាន)**

អ្នកដាក់ពាក្យបណ្តឹងទាមទារសំណង ដែលបានដាក់ទម្រង់ពាក្យបណ្តឹង ទាមទារសំណងចុងក្រោយ ដោយការពិនិត្យពេញលេញ អាចដាក់ឯកសារដែលគាំទ្របញ្ជាក់ពីចំនួន ដែលអះអាងថា នឹងជាចំនួនប្រាក់ខូចខាតនាថ្ងៃអនាគត ដោយសារការកំពប់ប្រេង ដែលរាប់បញ្ចូល ទាំងឯកសារដែលបង្ហាញពីវិធីគណនាការខូចខាតនៅថ្ងៃអនាគតនោះ រយៈពេលដែលទាមទារសំណងខូចខាតអនាគត និងរបាយការណ៍របស់អ្នកជំនាញ ឬការវិភាគដទៃទៀតដែលជាមូលដ្ឋានសម្រាប់ការគណនា។

**V. ឯកសារដែលត្រូវការចំពោះពាក្យបណ្តឹងទាមទារសំណងលើការបាត់បង់ការប្រើប្រាស់ធនធានធម្មជាតិដើម្បីចិញ្ចឹមជីវិត**

បុគ្គលណាក៏ដោយ ដែលទាមទារសំណងលើការបាត់បង់ការប្រើប្រាស់ធនធានធម្មជាតិដើម្បីចិញ្ចឹមជីវិត ដោយសារការកំពប់ប្រេង ត្រូវដាក់ឯកសារ ដែលរៀបរាប់ដូចខាងក្រោម។

**1. ឯកសារដែលកំណត់ពីការប្រើប្រាស់ធនធានធម្មជាតិដើម្បីចិញ្ចឹមជីវិត**

អ្នកទាមទារសំណងត្រូវផ្តល់រូបថត សេចក្តីបញ្ជាក់ សេចក្តីថ្លែងរបស់សាក្សី ឬឯកសារដទៃទៀត ដែលកំនត់ពីធនធានធម្មជាតិដែលទទួលរងផលប៉ះពាល់ ដែលប្រើប្រាស់ដោយអ្នកទាមទារសំណង មុនការកំពប់ប្រេង ហើយបញ្ជាក់ថា អ្នកទាមទារសំណងបានប្រើប្រាស់ និងពឹងផ្អែកលើធនធាននោះ ដើម្បីចិញ្ចឹមជីវិតរបស់អ្នកទាមទារសំណង។ ចិញ្ចឹមជីវិតមានអត្ថន័យថា ជាការចាំបាច់ដើម្បីគាំទ្រដល់ជីវិត។

**2. ឯកសារពីថ្លៃចំណាយរកជំនួស**

អ្នកទាមទារសំណងត្រូវផ្តល់ច្បាប់ចម្លងវិក្កយប័ត្រ និងឯកសារបញ្ជាក់ការចំណាយដទៃទៀតដើម្បីជំនួសធនធានធម្មជាតិ ដែលពីមុនពឹងផ្អែកដើម្បីចិញ្ចឹមជីវិត។

**3. ចំពោះពាក្យបណ្តឹងទាមទារសំណងចុងក្រោយដោយការពិនិត្យពេញលេញ — ឯកសារគាំទ្រការខូចខាតនាពេលអនាគត (ប្រសិនបើមាន)**

អ្នកដាក់ពាក្យបណ្តឹងទាមទារសំណង ដែលបានដាក់ទម្រង់ពាក្យបណ្តឹង ទាមទារសំណងចុងក្រោយ ដោយការពិនិត្យពេញលេញ អាចដាក់ឯកសារដែលគាំទ្របញ្ជាក់ពីចំនួន ដែលអះអាងថា នឹងជាចំនួនប្រាក់ខូចខាតនាថ្ងៃអនាគត ដោយសារការកំពប់ប្រេង ដែលរាប់បញ្ចូល ទាំងឯកសារដែលបង្ហាញពីវិធីគណនាការខូចខាតនៅថ្ងៃអនាគតនោះ រយៈពេលដែលទាមទារសំណងខូចខាតអនាគត និងរបាយការណ៍របស់អ្នកជំនាញ ឬការវិភាគដទៃទៀតដែលជាមូលដ្ឋានសម្រាប់ការគណនា។

**VI. ឯកសារដែលត្រូវការចំពោះពាក្យបណ្តឹងទាមទារសំណងលើរបួសរាងកាយ ឬមរណៈភាព**

បុគ្គលណាក៏ដោយ ដែលទាមទារសំណងដោយសាររបួសរាងកាយ ឬមរណៈភាព ដោយសារការកំពប់ប្រេង ត្រូវដាក់ឯកសារ ដែលរៀបរាប់ ដូចខាងក្រោម។

**1. ឯកសារស្តីពីរោគវិនិច្ឆ័យ**

អ្នកទាមទារសំណងត្រូវផ្តល់ឯកសារពីគ្រូពេទ្យ ដែលធ្វើរោគវិនិច្ឆ័យលើរបួសរាងកាយ/មរណៈភាព ដូចជាបញ្ជីមន្ទីរពេទ្យ ឬបញ្ជីពេទ្យ។

**2. ឯកសារដែលបញ្ជាក់ពីមូលហេតុរបួស ឬមរណៈភាព**

អ្នកទាមទារសំណងត្រូវផ្តល់ឯកសារពីគ្រូពេទ្យព្យាបាល ដែលរៀបរាប់ពីមូលហេតុរបួស/មរណៈភាព ដូចជាបញ្ជីមន្ទីរពេទ្យ បញ្ជីពេទ្យ ឬលិខិតថ្លែងសច្ចា។

**3. ឯកសារដែលបញ្ជាក់ពីទីកន្លែងរងរបួស ឬទទួលមរណៈភាព**

អ្នកទាមទារសំណងត្រូវផ្តល់ឯកសារដែលបង្ហាញពីទីតាំងភូមិសាស្ត្រ ដែលរងរបួស/ទទួលមរណៈភាព ដូចជា ច្បាប់ចម្លងនៃបញ្ជីរបស់និយោជក បញ្ជីមន្ទីរពេទ្យ ឬបញ្ជីពេទ្យ។

**4. ភស្តុតាងបញ្ជាក់ពីការចំណាយថ្លៃពេទ្យ**

អ្នកទាមទារសំណងត្រូវផ្តល់ឯកសារ ដែលបញ្ជាក់ពីការចំណាយថ្លៃពេទ្យណាក៏ដោយ ដែលបង់ដោយសាររបួសរាងកាយ/មរណៈភាព ដូចជាច្បាប់ចម្លងនៃបង្កាន់ដៃឱសថស្ថាន វិក្កយប័ត្រមន្ទីរពេទ្យ ឬវិក្កយប័ត្រពីគ្រូពេទ្យ។

**5. ភស្តុតាងបញ្ជាក់ពីការបាត់បង់សមត្ថភាព**

ប្រសិនបើមានពាក្យបណ្តឹងទាមទារការបាត់បង់សមត្ថភាព ត្រូវផ្តល់ភស្តុតាងពីលក្ខណៈ និងកម្រិតនៃការបាត់បង់សមត្ថភាពនោះ ដូចជាច្បាប់ចម្លងនៃបញ្ជីមន្ទីរពេទ្យ ឬបញ្ជីពេទ្យដទៃទៀតដែលបានពីការព្យាបាលអ្នកទាមទារសំណងនោះ។

**6. របួសរាងកាយ ក្នុងអំឡុងបំពេញការងារឱ្យកម្មវិធីនាវាឱកាស (Vessels of Opportunity)**

ប្រសិនបើរបួសកើតឡើង ក្នុងខណៈពេលបំពេញការងារឱ្យកម្មវិធីនាវាឱកាស ឬកម្មវិធីសម្អាតឆ្នេរសមុទ្រ ត្រូវផ្តល់ភស្តុតាងពីការជួលឱ្យធ្វើការ ដូចជាច្បាប់ចម្លងនៃចុងសន្លឹងប្រាក់ឈ្នួល និងរបាយការណ៍ពីឧបទ្ទវហេតុ ដែលទាក់ទងនឹងរបួស។

**7. ភស្តុតាងដែលចាំបាច់ចំពោះពាក្យបណ្តឹងទាមទារសំណងលើមរណៈភាព**

ប្រសិនបើមរណៈភាពត្រូវបានគេអះអាងថាបង្កឡើងដោយការកំពប់ប្រេង ត្រូវច្បាប់ចម្លងនៃសំបុត្រមរណៈភាព និងរបាយការណ៍កោសល្យវិច័យ ប្រសិនបើមាន។ ប្រសិនបើទទួលមរណៈភាពក្នុងខណៈនៅមន្ទីរពេទ្យ ឬអគារថែទាំដទៃទៀត ត្រូវផ្តល់បញ្ជីទាំងអស់ដែលទាក់ទងនឹងការស្នាក់នៅ ក្នុងមន្ទីរពេទ្យ ឬអគារនោះ។

**8. ឯកសារស្តីពីប្រាក់ពីធានារ៉ាប់រង ឬប្រភពដទៃទៀត**

អ្នកទាមទារសំណងត្រូវលើកឡើង និងផ្តល់ឯកសារពីចំនួនសំណង ប្រាក់បង់សងថ្លៃចំណាយ ឬប្រាក់ដទៃទៀតដែលទទួលបានចំពោះរបួស និង/ឬ ចំពោះការចំណាយព្យាបាលដោយសាររបួស ពីប្រភពណាមួយ ដូចជា ការធានារ៉ាប់រងសុខភាពឯកជន Medicare ឬ Medicaid ការធានារ៉ាប់រងសំណងកម្មករ ឬភាគីណាមួយ។

**9. ចំពោះពាក្យបណ្តឹងទាមទារសំណងចុងក្រោយដោយការពិនិត្យពេញលេញ— ឯកសារគាំទ្រការខូចខាតនាពេលអនាគត (ប្រសិនបើមាន)**

អ្នកដាក់ពាក្យបណ្តឹងទាមទារសំណង ដែលបានដាក់ទម្រង់ពាក្យបណ្តឹង ទាមទារសំណងចុងក្រោយ ដោយការពិនិត្យពេញលេញ អាចដាក់ឯកសារដែលគាំទ្របញ្ជាក់ពីចំនួន ដែលអះអាងថានឹងជាចំនួនប្រាក់ខូចខាតនាថ្ងៃអនាគត ដោយសារការកំពប់ប្រេង ដែលរាប់បញ្ចូល ទាំងឯកសារដែលបង្ហាញពីវិធីគណនាការខូចខាតនៅថ្ងៃអនាគតនោះ រយៈពេលដែលទាមទារសំណងខូចខាតអនាគត និងរបាយការណ៍របស់អ្នកជំនាញ ឬការវិភាគដទៃទៀតដែលជាមូលដ្ឋានសម្រាប់ការគណនា។

## VII. ឯកសារដែលត្រូវការចំពោះអ្នកតំណាងរបស់អ្នកទាមទារសំណង

**ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងទាមទារសំណងតាងនាមឱ្យមរណៈជន ជនអសមត្ថភាពផ្លូវច្បាប់ ឬអនីតិជន ក្រោមច្បាប់រដ្ឋ ឬយុត្តាធិការ ដែលអនីតិជនរង់នៅ អ្នកក៏ត្រូវដាក់ឯកសារ ដូចខាងក្រោម ផងដែរ។ ដើម្បីទទួលបានទម្រង់ពាក្យបណ្តឹងដែលតម្រូវដោយស្ថាបន GCCF ដែលបានរៀបរាប់ខាងក្រោម សូមចូលទៅវែបសាយ www.gulfcoastclaimsfacility.com ទូរសព្ទមកលេខឥតគិតថ្លៃ 1-800-916-4893 ឬចុះទៅការិយាល័យរបស់ស្ថាប័ន GCCF។**

**1. អ្នកតំណាងរបស់អ្នកទាមទារសំណងដែលបាត់បង់ជីវិត**

ត្រូវផ្តល់ច្បាប់ចម្លងនៃដីកាតុលាការ ឬឯកសារដទៃទៀត ដែលចេញដោយមន្ត្រី និងដែលបង្ហាញពីការតែងតាំងជាអ្នកតំណាងទ្រព្យរបស់អ្នកទាមទារសំណងដែលបាត់បង់ជីវិត។ ប្រសិនបើមិនអាចយកបានឯកសារនេះ អ្នកទាមទារសំណងត្រូវដាក់លិខិតថ្លែងសច្ចាពីទាយាទ ដោយប្រើទម្រង់ពាក្យ ដែលតម្រូវដោយស្ថាបន GCCF។

**2. អ្នកតំណាងរបស់អ្នកទាមទារសសំណងដែលអសមត្ថភាពផ្លូវច្បាប់**

ត្រូវផ្តល់ច្បាប់ចម្លងនៃដីកាតុលាការ ឬឯកសារដទៃទៀត ដែលចេញដោយមន្ត្រី និងដែលបង្ហាញពីការតែងតាំងជាអណាព្យាបាល ឬអ្នកតំណាងពេញសិទ្ធិដទៃទៀតរបស់អ្នកទាមទារសំណងដែលអសមត្ថភាព។ ប្រសិនបើមិនអាចយកបានឯកសារនេះ អ្នកទាមទារសំណងត្រូវដាក់លិខិតថ្លែងសច្ចាពីអាណាព្យាបាលភាព ដោយប្រើទម្រង់ពាក្យបណ្តឹងដែលតម្រូវដោយស្ថាបន GCCF។

**3. អ្នកតំណាងរបស់អ្នកទាមទារសំណងដែលអនីតិជន**

ត្រូវផ្តល់ច្បាប់ចម្លងនៃដីកាតុលាការ ឬឯកសារដទៃទៀត ដែលចេញដោយមន្ត្រី និងដែលបង្ហាញពីការតែងតាំងជាអណាព្យាបាល ឬអ្នកតំណាងពេញសិទ្ធិដទៃទៀតរបស់អ្នកទាមទារសំណងដែលមិនទាន់គ្រប់អាយុតាមច្បាប់។ ប្រសិនបើមិនអាចយកបានឯកសារនេះ អ្នកទាមទារសំណងត្រូវដាក់លិខិតថ្លែងសច្ចាពីភាពជាមាតាបិតា ឬសមត្ថភាពឃុំគ្រង ដោយប្រើទម្រង់ពាក្យបណ្តឹងដែលតម្រូវដោយស្ថាបន GCCF។

ឯកសារភ្ជាប់E

**ទម្រង់បែបបទលិខិតជំនួញ**
[កាលបរិច្ឆេទ]

[អ្នកទាមទារ/ឈ្មោះមេធាវី]
[អាសយដ្ឋានអ្នកទាមទារសំណង/មេធាវី 1]
[អាសយដ្ឋាន 2]
[លេខប្រៃសណីយ៍ទីក្រុង រដ្ឋ]

**ឆ្លើយតបៈ លិខិតសម្រេចចុងក្រោយស្តីពីបណ្តឹងទាមទារសំណងពាក់កណ្តាលទី/សំណងចុងក្រោយ**
**[ឈ្មោះអ្នកទាមទារសំណង:]**
**[អត្តលេខអ្នកទាមទារសំណង:]**

ជូនចំពោះអ្នកប្តឹងទាមទារសំណងៈ

ស្ថាបនសម្របសម្រួលបណ្តឹងតំបន់ឈូងសមុទ្រ ("GCCF") គឺជាស្ថាបនផ្លូវការសម្រាប់បុគ្គល ឬអាជីវកម្មដាក់ពាក្យបណ្តឹងទាមទារ សំណងថ្លៃចំណាយ និងការខូចខាតដែលបណ្តាលមកពីឧបទ្ទវហេតុនៃការកំពប់ប្រេងនៅបាតសមុទ្រកាលពីថ្ងៃទី20 ខែមេសា ឆ្នាំ 2010។ ស្ថាបន GCCF និងមន្ត្រីគ្រប់គ្រងផ្នែករដ្ឋបាលនៃពាក្យបណ្តឹងទាមទារ លោក Kenneth R. Feinberg ដើរតួនិងតំណាងឱ្យក្រុមហ៊ុន BP Exploration & Production, Inc. ("BP") ក្នុងការបំពេញនូវកាតព្វកិច្ចទទួលខុសត្រូវតាមផ្លូវច្បាប់របស់ក្រុមហ៊ុន BP ជា "ភាគីទទួលខុសត្រូវ" ស្ថិតក្រោមច្បាប់បំពុលដោយសារប្រេងឆ្នាំ 1990 (Oil Pollution Act នៃឆ្នាំ 1990)។

*រាល់អ្នកទាមទារសំណងទាំងអស់មានសិទ្ធិគ្រប់គ្រាន់ក្នុងការពិគ្រោះជាមួយមេធាវីដែលខ្លួនបានជ្រើសរើស មុនធ្វើការទទួលយកដំណោះស្រាយណាមួយ ឬក៏ចុះហត្ថលេខាលើលិខិតដោះបន្ទុកកាតព្វកិច្ច។*

លិខិតប្តេជ្ញា (Determination Letter) គឺជាលិខិតជូនដំណឹងផ្លូវការពីGCCF. GCCF បានត្រួតពិនិត្យឡើងវិញនូវទម្រង់ទាមទារសំណងពាក់កណ្តាលទី និង/ឬ ត្រួតពិនិត្យវិញទាំងស្រុងនូវទម្រង់ទាមទារសំណងចុងក្រោយដែលអ្នកដាក់ជូន។ លិខិតនេះប្រាប់អ្នកពីលទ្ធផលនៃការត្រួតពិនិត្យឡើងវិញនិងរៀបរាប់ពីជម្រើសបច្ចុប្បន្ន របស់អ្នក។ ប្រសិនបើលោកអ្នកមិនឯកភាពនឹងសេចក្តីសម្រេចរបស់ GCCF ទាក់ទងនឹងបណ្តឹងទាមទារ ប្រាក់សំណងជាមុនសម្រាប់តម្រូវការបន្ទាន់ លោកអ្នកអាចមានសិទ្ធិដាក់ពាក្យបណ្តឹងទៅកាន់ National Pollution Funds Center ("NPFC") ការិយាល័យឆ្មាំងឈូងសមុទ្រ (Coast Guard) ដែលទទួលបន្ទុកលើការវាយតម្លៃ និងអនុម័តបណ្តឹងទាមទារសំណងក្រោមច្បាប់បំពុលដោយសារប្រេង (OPA) ឬក៏លោកអ្នកអាចមានសិទ្ធិដាក់ពាក្យបណ្តឹងទៅតុលាការ ក្នុងនីតិវិធីបណ្តឹងពិសេសរបស់រដ្ឋសហព័ន្ធ ដែលកំពុងរង់ចាំការជំនុំជម្រះនៅចំពោះមុខតុលាការ United States District Court សម្រាប់ the Eastern District of Louisiana ក្នុងរឿង*ក្តី Oil Spill by the Oil Rig "Deepwater Horizon" នៅឈូងសមុទ្រម៉ិចស៊ិក ថ្ងៃទី20 ខែមេសា ឆ្នាំ2010*(MDL No. 2179)។ នីតិវិធីបណ្តឹងពិសេសរបស់រដ្ឋសហព័ន្ធគឺជាការផ្តុំបញ្ចូលគ្នានូវពាក្យបណ្តឹងផ្សេងក្នុងរដ្ឋសហព័ន្ធផ្សេងៗដែលកើតចេញពីការកំពប់ប្រេង។ ព័ត៌មានទូទៅស្តីពីនីតិវិធីដាក់ពាក្យបណ្តឹងទាមទារនៅ NPFC អាចរកបានពីប្រធាន National Pollution Funds Center, NPFC MS 7100, U.S. Coast Guard, 4200 Wilson Blvd., Suite 1000, Arlington, VA 20598-7100, (800) 280-7118, ឬពីវែបសាយ NPFC តាមអាសយដ្ឋាន www.uscg.mil/npfc/claims។ ព័ត៌មានទាក់ទងនឹងនីតិវិធីបណ្តឹងពិសេសរបស់សហព័ន្ធអាចរកបានពីគេហទំព័រwww.laed.uscourts.gov។

I. **<u>សេចក្តីសម្រេចចុងក្រោយនៃការទាមទារសំណង និងការគិតគូរការខាតបង់</u>**.

